# បត្តិទានមយៈ

## បុណ្យកើតអំពីការចែកបុណ្យ

## ភាគទី ៦




រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស.២៥៥៧

ឈ្មោះសៀវភៅ **បត្តិទានមយៈ**

រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

ចេញផ្សាយ លើកទី ១

កាលបរិច្ឆេទ ព.ស. ២៥៥៧

ទីកន្លែងធ្វើ វត្តនិគ្រោធវ័នគល់ទទឹងភូមិកោះក្របី សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# អារម្ភកថា

**ធម្មតា ការចែករំលែករបស់របរផ្សេងៗឱ្យទៅគេ ឱ្យកាន់តែច្រើន អស់ក៏កាន់តែច្រើនដែរ** ប៉ុន្តែការចែករំលែកបុណ្យកុសលវិញ ចែកឱ្យគេកាន់តែច្រើន អ្នកឱ្យនោះរឹងរិតតែបានបុណ្យកាន់តែច្រើនដែរ លោកប្រៀបឧបមាដូចជាពន្លឺភ្លើងទៀនមួយដើមបើយើងយកទៀនផ្សេងទៀតទៅអុជ ចម្លងបន្ត គឺរឹងរឹតតែធ្វើឱ្យភ្លឺកាន់តែខ្លាំងឡើងថែមទៀត ឯការចែកបុណ្យដល់អ្នកដទៃ ក៏មានឧបមាដូច្នោះដែរ ។ ម្យ៉ាងទៀត ការចែករំលែកផលបុណ្យនេះគឺសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលចែកឋានស្លាប់ទៅហើយ មិនបានឧទ្ទិសជូនចំណែកផលបុណ្យនេះ ទៅដល់ពួកគាត់ទេ ទោះបីយើងធ្វើបុណ្យធំប៉ុណ្ណាក៏ដោយ ក៏ពួកគាត់មិនអាចទទួលបានបាយ ទឹក នំ ចំណី ឬរបស់អ្វី សូម្បីតែបន្តិចឡើយ ម្ល៉ោះហើយ បានជារាល់ពេលដែលគេបាន ដឹកនាំឧទ្ទិសជូននូវចំណែកផលបុណ្យនេះ ដល់បុព្វការីជនដែលស្លាប់ ចែកឋានទៅហើយ ឬសព្វសត្វទាំងឡាយទាំងពួង ឱ្យបានអនុមោទនាទទួលយកនូវចំណែកផលបុណ្យនេះ ដើម្បីឱ្យបានរួចផុតចាកទុក្ខ បានជួបតែសេចក្តីសុខចម្រើនតទៅទៀតទៅ ។ ឯការឧទ្ទិសជូនចំណែកផលបុណ្យតាមលោកអាចារ្យនេះ គឺត្រូវឧទ្ទិសថាតាមឱ្យចេញពីក្នុងចិត្តខ្លួនឯង ដោយស្មោះ មិនមែនថាតែមាត់ឱ្យតែព្ញៗបង្គ្រប់ៗកិច្ចនោះទេ ។

*សៀវភៅ* **បត្តិទានមយៈនេះ** *ខ្ញុំសង្ឃឹមថា នឹងបានជាផ្លូវចង្អុលបង្ហាញអំពីអានិសង្សខ្លះៗ នៃការធ្វើបុណ្យរបស់ពុទ្ធបរិស័ទទាំងឡាយ ដែលជាអ្នកប្រាថ្នានូវបុណ្យ ប្រាថ្នានូវសេចក្ដីសុខនោះ។*

*ពេលធ្វើបុណ្យរួចហើយ កុំភ្លេចជូនផលបុណ្យនោះ ដល់សព្វសត្វទូទៅទាំងអស់ផង ជាពិសេសកុំភ្លេចជូនបុណ្យដល់ព្រះឥន្ទ្រាធិរាជ ស្ដេចទេវតា ស្ដេចចតុលោកបាលទាំងបួន និងស្ដេច-យមរាជផងណា...! ពីព្រោះទេវតាត្រូវការបុណ្យណាស់ ពេញចិត្តនឹងបុណ្យណាស់ អំពីមនុស្សដែលបានធ្វើបុណ្យៗឯចំណែកស្ដេចយមរាជវិញ រឹតតែសំខាន់ទៅទៀត ព្រោះក្រែងលោភ្លាត់គតិណាមួយ បានទៅជួបជាមួយស្ដេចមយរាជ, គ្រានោះ ស្ដេចយមរាជនឹងសួរថា អ្នកធ្លាប់បានធ្វើបុណ្យអ្វីខ្លះ ខណៈនោះបើយើងនឹកឃើញដល់បុណ្យ យើងនឹងរួចផុតអំពីនរកភ្លាម តែបើយើងនឹកមិនឃើញទេ ស្ដេចយមរាជនឹងរំពឹងគិតថា តើអ្នកនេះធ្វើបុណ្យហើយ ធ្លាប់ផ្សាយចំណែកផលបុណ្យដល់អាត្មាអញទេ បើយើងធ្លាប់ផ្សាយផលបុណ្យដល់ស្ដេចយមរាជ, ស្ដេចយមរាជនឹងប្រាប់ដល់យើង ហើយយើងនឹងរួចផុតអំពីសេចក្ដីទុក្ខភ្លាម ។*

**សូមអនុមោទនា** !!!!

*ថ្ងៃ ៧ រោច ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧*

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

# បញ្ជីមាតិកា


បុណ្យកើតអំពីការចែកបុណ្យ ......................................១

ការឧទ្ទិសបុណ្យដល់អ្នកដែលស្លាប់ទៅ .........................៣

ទក្ខិណាសូត្រ ........................................................... ៧

ប្រវត្តិព្រះអនុរុទ្ធត្ថេរ ................................................ ១១

គាថាអនុមោទនា.................................................... ២៦

តិរោកុឌ្ឌសូត្រ......................................................... ២៨

មាតាសូត្រៈ.......................................................... ៦៨

ការចែកបុណ្យ ២ យ៉ាង .............................................៧៥

គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ...........៧៨



## ការជូនបុណ្យ

*កូនជាទីស្រឡាញ់!*

*កូនត្រូវសិក្សានូវចំណុចនៃការជូនបុណ្យទាំង ៥ នេះគឺៈ*

*១-ជូនបុណ្យឧទ្ទិសបុណ្យ គឺជាទានមួយ៉ាងដ៏សំខាន់ ។*

*២-ជូនបុណ្យសម្រេចដោយទឹកចិត្តមេត្តាព្រមដោយការយល់ដឹង ។*

*៣-ត្រូវនឹកប្រាថ្នាឱ្យសព្វសត្វបានប្រយោជន៍សុខពិតៗ ។*

*៤-ត្រូវនឹកប្រាថ្នាឱ្យសព្វសត្វបានផុតចាកពីទុក្ខលំបាក ។*

*៥-កុំបង្អួតខ្លួនឯង ត្រូវប្រាថ្នាឱ្យគេត្រេកអរទទួលបុណ្យ ។*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។**
**សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ។**

# បត្តិទានមយៈ

## *បុណ្យកើតអំពីការចែកបុណ្យ*

***បត្តិទាន*** *សម្តែងវចនត្ថៈថា* **បត្តញ្ញាតិ បត្តិ បត្តិយា ជាធំ បត្តិជាធំ** *= ធម្មជាតិណាដែលអ្នកធ្វើបានដល់ហើយ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា* **បត្តិ** *បានដល់ ទាន សីល ភាវនា ដែលកើតឡើងហើយក្នុងសន្តានរបស់ខ្លួន ការឱ្យចំណែកបុណ្យដែលខ្លួនបានមកឈ្មោះថា* **បត្តិទាន** *បានដល់ ការឧទ្ទិសចំណែកបុណ្យឱ្យដល់មាតាបិតា គ្រូអាចារ្យ ញាតិ បងប្អូន រហូតសព្វសត្វទាំងពួងដែលស្លាប់ទៅហើយ ។*

*តាមវចនត្ថៈនេះ ជាការសម្តែងដោយបុគ្គលាធិដ្ឋាន តែកាលនឹងសម្តែងដោយធម្មាធិដ្ឋានហើយ ក៏មានដូច្នេះ* **បត្តឹ ទទន្តិ ឯតេនាតិ បត្តិទានំ** *អ្នកចិត្តបុណ្យទាំងឡាយ រមែងឱ្យចំណែកបុណ្យដែលខ្លួនបាន មកដល់អ្នកដែលរំលោងខន្ធ ស្លាប់ទៅកាន់បរលោកហើយ អ្នកដែលនៅមានជីវិតរស់នៅដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិដែលជាហេតុនៃការឱ្យនោះ ឈ្មោះថា* **បត្តិទាន** *បានដល់ ចេតនាដែលនៅក្នុងមហាកុសលចិត្តុប្បាទ ដែលកើត*

ឡើងក្នុងខណៈដែលតាំងចិត្តឧទ្ទិសចំណែកបុណ្យ ។

សួរថា ការឧទ្ទិសចំណែកបុណ្យឱ្យដល់បុគ្គលដទៃ ដូច្នោះហើយ បុណ្យនោះនឹងកាត់បន្ថយចុះទៅទេ ?

ឆ្លើយថា មិនកាត់បន្ថយចុះឡើយ យ៉ាងណា មានតែនឹងត្រឡប់ បង្កើនឡើងបន្ថែមឡើងទៀត ដូច្នោះ ក៏ព្រោះថា ការឱ្យនូវបុណ្យនោះ ផ្សេងគ្នាពីការឱ្យវត្ថុដែលពោលថា មានតែនឹងបង្កើនឡើង ថែមឡើងទៅនោះ ពាក្យនេះ ឧបមាហាក់បីដូចការអុចទៀនបន្ថែមឡើង គឺបុគ្គលអុជទៀនទុក ១ ដើម សូម្បីបើថា នាំទៀនដទៃៗមកអុជតមានចំនួនច្រើនរយ ច្រើនពាន់ដើមក៏ដោយ ពន្លឺភ្លឺច្បាស់ដែលមាននៅក្នុងទីនោះ ជាមួយទៀនដើមដំបូង ក៏មិនបានអស់ទៅដោយប្រការណា មានតែបានទទួលពន្លឺភ្លឺច្បាស់បន្ថែមឡើងពីពន្លឺទៀនទាំងនោះជាទ្វេគុណយ៉ាងណា ការឧទ្ទិសចំណែកបុណ្យឱ្យដល់បុគ្គលដទៃក៏រមែងជួយធ្វើឱ្យកុសល ដែលខ្លួនបានមក មានអំណាចច្រើនក្រៃលែងៗឡើង ទៅគ្រប់កាលដែលធ្វើការឧទ្ទិសឱ្យ ដូច្នោះ ។

ម្យ៉ាងទៀត ការចែកបុណ្យកុសលឱ្យដល់អ្នកដទៃ គឺជាការប្រដៅចិត្តមួយផ្នែក ដើម្បីកុំឱ្យចិត្តគិតបានអ្វីៗតែខ្លួនឯង ត្រូវចេះបែងចែករបស់ប្រសើរឱ្យអ្នកដទៃ ទូន្មានចិត្តឱ្យចេះអើពើក្នុងអំពើល្អដោយយកចិត្តទុកដាក់ ការជូនបុណ្យ គឺជូនដោយចិត្ត

មេត្តា ដោយចិត្តទន់ភ្លន់ ជូនដើម្បីឱ្យអ្នកដទៃ បានបុណ្យពិតៗ ព្រោះអនុមោទនា ។

## ការឧទ្ទិសទានដល់អ្នកដែលស្លាប់ទៅ

នៅក្នុង**ជាណុស្សោណិសូត្រ** ព្រះត្រៃបិដកលេខ ៥១ ទំព័រ ១៣៩ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **ការឧទ្ទិសទានដល់អ្នកស្លាប់** ជាមួយនឹងព្រាហ្មណ៍ថា៖

លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក នាំឱ្យកើតសេចក្តីស្និតស្នាលហើយ អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឱ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា ទាននេះសូមឱ្យសម្រេចផលដល់ប្រេតទាំងឡាយជាញាតិសាលោហិត ពួកប្រេតទាំងឡាយជាញាតិសាលោហិតសូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះបានដែរឬទេ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។

(ជាណុស្សោណិព្រាហ្មណ៍) បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរ តើដូចម្តេច ។

(ព្រះអង្គ) ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណាជាអាហារសម្រាប់សត្វទាំងឡាយកើតក្នុងនរក សត្វនរកនោះតែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះ ឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថា **ទីមិនិគួរ ។**

ម្នាលព្រាហ្មណ៍មួយទៀត បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ

មានសេចក្ដីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះដោយអាហារនោះ សត្វតិរច្ឆាននោះឋិតនៅក្នុងទីនោះដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ ។

ម្នាលព្រាហ្មណ៍ចំណែកឯបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាប ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្ដីយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណា ជាអាហារសម្រាប់ពួកទេវតា ទេវតានោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោកនេះជាអ្នក

វៀរស្រឡះចាកបាណាតិបាត ។ល។ មានសេចក្តីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណា ជាអាហារសម្រាប់ពួកទេវតា ទេវតានោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។

សូមចំណាំថា ៤ ចំណុចខាងលើនេះ ញាតិឧទ្ទិសទានទៅមិនអាចទទួលអនុមោទនាបានទេ ។

ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្រអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឱ្យនូវទានណាដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយសារអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះសម្រេច

ផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីគួរ ។

ជាណុស្សោណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះមិនបានទៅកើតក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ។

ព. អើព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់ គេគង់ទៅកើតទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាននោះ ។

ជា. បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណាបរិភោគទាននោះ ។

ព. នៃព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយជាញាតិ សាលោហិតដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឱ្យទានមិនមែនជាគ្មានផលទេ ។

## **ទក្ខិណាសូត្រ**

នៅក្នុងព្រះត្រៃបិដកលេខ ៤២ ទំព័រ ១៩៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពីទក្ខិណាវិសុទ្ធិ៤ ប្រការ សេចក្ដីថា៖

ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិ (សេចក្ដីបរិសុទ្ធិនៃ

ទក្ខិណាទាន)នេះ មាន ៤ ប្រការ ។ ទក្ខិណាវិសុទ្ធិ ៤ ប្រការ ដូចម្ដេចខ្លះ ។

១-អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធិអំពីទាយក មិនបរិសុទ្ធិអំពីបដិគ្គាហកក៏មាន ។

២-អត្ថិ ភិក្ខវេ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធិអំពីបដិគ្គាហក មិនបរិសុទ្ធិអំពីទាយកក៏មាន ។

៣-អត្ថិ ភិក្ខវេ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ម្នាលភិក្ខុទាំងឡាយ ទក្ខិណាមិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទ្ធិអំពីបដិគ្គាហកក៏មាន ។

៤-អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធិអំពីទាយកផង បរិសុទ្ធិអំពីបដិគ្គាហកផងក៏មាន ។

**សេចក្ដីអធិប្បាយទក្ខិណាវិសុទ្ធិ ៤ ប្រការ**

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធិអំពីទាយក មិនបរិសុទ្ធិ អំពីបដិគ្គាហក ដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ មានសីលមាន កល្យាណធម៌ តែបដិគ្គាហក ជាអ្នកទ្រុស្តសីល មានបាប

ធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាបរិសុទ្ធិអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក ។

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធិអំពីបដិគ្គាហក មិនបរិសុទ្ធិអំពីទាយក ដូចម្ដេច ?

ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ តែបដិគ្គាហក ជាអ្នកមានសីល មានកល្យាណធម៌ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា ទក្ខិណាបរិសុទ្ធិអំពីបដិគ្គាហក មិនបរិសុទិអំពីទាយក ។

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាមិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទ្ធិអំពីបដិគ្គាហក ដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីលមានបាបធម៌ទាំងបដិគ្គាហក ក៏ជាអ្នកទ្រុស្តសីល មានបាបធម៌ដែរ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាមិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទិអំពីបដិគ្គាហក ។

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធិអំពីទាយកផង បរិសុទ្ធិអំពីបដិគ្គាហកផង តើដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងសាសនានេះ ជាអ្នកមានសីល មានកល្យាណធម៌ បដិគ្គាហក ក៏ជាអ្នកមានសីល មានកល្យាណធម៌ដូចគ្នា ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាបរិសុទ្ធិ អំពីទាយកផង អំពីបដិគ្គាហកៈផង ។

ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិមាន ៤ ប្រការប៉ុណ្ណោះឯង ។

## អដ្ឋកថា

បទថា **ទក្ខិណាវិសុទ្ធិយោ** បានដល់ ហេតុទាំងឡាយនៃសេចក្តីបរិសុទ្ធិរបស់ទក្ខិណា គឺទាន ។

បទថា **ទាយកតោ វិសុទ្ធិជ្ឈតិ** សេចក្តីថា រមែងបរិសុទ្ធិដោយសេចក្តីដែលមានផលច្រើន ។

បទថា **កល្យាណធម្មោ** គឺជាអ្នកមានធម៌ល្អ ។

បទថា **បាបធម្មោ** គឺជាអ្នកមានធម៌អាក្រក់ ។

ក្នុងបទថា **ទាយកតោ វិសុជ្ឈតិ** នេះ គួរពោលដល់ព្រះវេស្សន្តរមហារាជ ។ បានឮថា ព្រះវេស្សន្តរមហារាជនោះ ឱ្យកូនទាំងពីរ(គឺជាលី និងគ្រឹស្នា) ដល់ព្រាហ្មណ៍ឈ្មោះជូជក់ ធ្វើឱ្យមហាប្រថពីញាប់ញ័រ ។

បទថា **បដិគ្គាហកតោ វិសុទ្ធិជ្ឈតិ** នេះគួរពោលដល់អ្នកនេសាទ ដែលរស់នៅក្បែរស្ទឹងកល្យាណី ។ បានឮថា អ្នកនេសាទនោះ បានថ្វាយបិណ្ឌបាតបីដង ដល់ព្រះទីឃសុមនត្ថេរៈ (គ្រា)ដេកនៅលើគ្រែមរណៈ បានពោលថា បិណ្ឌបាតដែលបាន

ថ្វាយដល់លោកម្ចាស់ទីឃសុមនត្ថេរៈ (អាច)លើកអាត្មាអញឡើងបាន ។

ក្នុងបទថា **នេវ ទាយកតោ** នេះ គួរពោលដល់នាយព្រានអ្នករស់នៅក្នុងស្រុកវឌ្ឍនៈ បានឮថា នាយព្រាននោះ កាលធ្វើបុណ្យឧទ្ទិសដល់មិត្តមួយនាក់ដែលស្លាប់ទៅ ទើបបានថ្វាយទានដល់បដិគ្គាហក ដែលទ្រុស្តសីលម្នាក់រហូត ៣ ដង ។ ក្នុងលើកទី ៣ អមនុស្ស(អ្នកស្លាប់ទៅ កើតជាប្រេត)ស្រែកថា បដិគ្គាហកទ្រុស្តសីល ប្លន់យើងហើយ ដូច្នេះ ។ ទក្ខិណាដែលអាចសម្រេចដល់អ្នកស្លាប់បាននោះ គឺត្រូវតែជាទក្ខិណា ដែលថ្វាយដល់ភិក្ខុអ្នកមានសីល ។

ក្នុងបទថា **ទាយកតោ ចេវ បដិគ្គាហកតោ ច វិសុទ្ធិជ្ឈតិ** នេះ បណ្ឌិតគួរពោលដល់អសទិសទាន ។

## ប្រវត្តិព្រះអនុរុទ្ធត្ថេរ

បទថា **ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ** សេចក្តីថា ត្រាស់ថា ព្រះអនុរុទ្ធត្ថេរជាកំពូលលើភិក្ខុទាំងឡាយ អ្នកមានចក្ខុទិព្វ គប្បីជ្រាបថា ព្រះអនុរុទ្ធត្ថេរនោះជាអ្នកប្រសើរបំផុត ឬព្រោះជាអ្នកមានសេចក្តីជំនាញ ដែលសន្សំទុកហើយ។បានថាព្រះថេរៈវៀរតែវេលាឆាន់ប៉ុណ្ណោះ វេលាដែលនៅសល់ ចម្រើនអាលោកកសិណាត្រួតមើលពួកសត្វ ដោយទិព្វចក្ខុតែម្យ៉ាង ដូច្នោះ ព្រះថេរៈនេះទើបឈ្មោះថា

ជាកំពូលរបស់ភិក្ខុទាំងឡាយ អ្នកមានទិព្វចក្ខុ ឬព្រោះជាអ្នកមាន សេចក្ដីជំនាញដែលសន្សំទុករហូតដល់អស់មួយថ្ងៃនិងយប់។ម្យ៉ាង ទៀតជាកំពូលរបស់ភិក្ខុ ដែលមានទិព្វចក្ខុដែលនៅសល់ ឬព្រោះ ប្រាថ្នាទុករហូតដល់អស់សែនកប្ប ក៏ក្នុងរឿងបុព្វកម្មរបស់លោក ក្នុងសេចក្ដីនោះ មានរឿងដែល នឹងពោលតាមលំដាប់ដូចតទៅះ

សេចក្ដីពិស្ដារថា គ្រាព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរ នុ៎ះឯង កុលបុត្រសូម្បីនេះបានទៅនឹងមហាជនអ្នកទៅកាន់វិហារ ដើម្បីស្ដាប់ធម៌ខាងក្រោយភត្តាហារ ។ ក៏គ្រានោះ កុលបុត្រនេះបាន ជាកុដុម្ពីអ្នកធំក្រៃលែងម្នាក់ មិនប្រាកដឈ្មោះ ។ គេថ្វាយបង្គំព្រះ ទសពលហើយឈរចុងបរិស័ទស្ដាប់ធម្មកថា។ ព្រះសាស្ដាទ្រង់បន្ត ព្រះធម៌ទេសនាតាមអនុសន្ធិហើយ ទ្រង់ស្ថាបនាភិក្ខុដែលមានទិព្វ ចក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ។ លំដាប់នោះ កុដុម្ពីបានមាន ត្រិះរិះដូច្នេះថាភិក្ខុនេះធំហ្ន៎ព្រះសាស្ដាទ្រង់តាំងទុកក្នុងភាពប្រសើរ របស់ភិក្ខុដែលមានទិព្វចក្ខុនោះឯង ដោយប្រការយ៉ាងនេះ ឱហ្ន៎ សូម្បីយើងក៏គប្បីជាអ្នកប្រសើររបស់ភិក្ខុ ដែលមានចក្ខុទិព្វក្នុងព្រះ សាសនារបស់ព្រះពុទ្ធដែលនឹងឧប្បត្តិក្នុងអនាគតដូច្នេះហើយ កើត សេចក្ដីគិតដូច្នេះឡើង ដើរចូលទៅចន្លោះបរិស័ទ ទូលនិមន្តព្រះដ៏ មានព្រះភាគនឹងព្រះភិក្ខុមួយសែន ដើម្បីសោយក្នុងថ្ងៃស្អែក។ ក្នុង ថ្ងៃស្អែកឡើងក៏ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន

គិតថា យើងប្រាថ្នាតំណែងធំ ទើបទូលនិមន្តក្នុងថ្ងៃនេះ ដើម្បីសោយចង្ហាន់ក្នុងថ្ងៃស្អែកនេះ ហើយធ្វើមហាទានឱ្យប្រព្រឹត្តទៅដល់ ៧ ថ្ងៃ ដោយទំនងនោះឯង ថ្វាយសំពត់យ៉ាងល្អចំពោះព្រះដ៏មានព្រះភាគ ព្រមទាំងបរិវារហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គធ្វើសក្ការៈនេះ ដើម្បីប្រយោជន៍ដល់ទិព្វសម្បត្តិ ឬមនុស្សសម្បត្តិក៏ទេ ក៏ព្រះអង្គទ្រង់តាំងភិក្ខុណាទុក ក្នុងតំណែងជាកំពូលរបស់ភិក្ខុដែលមានទិព្វចក្ខុក្នុង ៧ ថ្ងៃដែលកន្លងមកពប់ពីថ្ងៃនេះ សូម្បីខ្ញុំព្រះអង្គក៏គប្បីជាកំពូលរបស់ភិក្ខុដែលមានទិព្វចក្ខុដូចភិក្ខុអង្គនោះ ក្នុងព្រះសាសនារបស់ព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគតកាលដូច្នេះហើយ ក្រាបចុះទៀបព្រះបាទរបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ត្រួតមើលក្នុងអនាគត ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់គេសម្រេច ទើបត្រាស់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ក្នុងទីបំផុតសែនកប្បក្នុងអនាគត ព្រះពុទ្ធព្រះនាមថាគោតម នឹងឧប្បត្តិឡើង លោកនឹងមានឈ្មោះថាអនុរុទ្ធៈជាកំពូលរបស់ភិក្ខុដែលមានទិព្វចក្ខុ ក្នុងព្រះសាសនារបស់ព្រះពុទ្ធ ព្រះនាម គោតមនោះ កាលត្រាស់យ៉ាងនេះហើយ ទ្រង់ធ្វើកត្តានុមោទនាស្តេចត្រឡប់ទៅព្រះវិហារ ។

ចំណែកកុដុម្ពីធ្វើកម្មល្អមិនដាច់ឡើយ ដរាបដែលព្រះពុទ្ធទ្រង់នៅមានព្រះជន្ម កាលព្រះសាស្តាបរិនិព្វានហើយ កាលសាង

ចេតិយមាសប្រមាណ ៧ យោជន៍សម្រេចហើយ ទើបចូលទៅរកភិក្ខុសង្ឃសួរថា លោកម្ចាស់ តើអ្វីជាបរិកម្មរបស់ទិព្វចក្ខុ ។ ភិក្ខុសង្ឃប្រាប់ថា ឧបាសក គួរឱ្យប្រទីប ។ ឧបាសកពោលថា ល្អណាស់ លោកម្ចាស់ ខ្ញុំព្រះករុណានឹងធ្វើ ទើបឱ្យសាងដើមប្រទីបមួយន្ទំដើម ដើម្បីប្រទីបមួយន្ទំមុន, បន្ទាប់អំពីនោះសាងឱ្យ តូចជាងនោះ រួមសេចក្ដីថា បានសាងដើមប្រទីបច្រើនពាន់ដើម ។ ចំណែកប្រទីបដែលនៅសល់ប្រមាណមិនបាន ។ គេធ្វើកល្យាណ-កម្ម យ៉ាងនេះរហូតអស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កន្លងទៅសែនកប្ប ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធកើតក្នុងផ្ទះកុដុម្ពីជិតក្រុងពារាណសី កាលព្រះសាស្ដាបរិនិព្វានកាលសាងចេតិយប្រមាណ ១យោជន៍រួចស្រេចហើយ ឱ្យសាងភាជន៍សំរិតជាច្រើន បញ្ចុះទឹកដោះថ្លាពេញ ឱ្យដាក់ប្រឆេះចង្កៀងរៀរ ១ ធ្នាប់ៗ ត្រង់កណ្ដាល ឱ្យអុជភ្លើងឡើងជុំវិញព្រះចេតិយឱ្យកណ្ដាប់មាត់ទល់គ្នា ឱ្យសាងភាជន៍សំរិតធំជាងគេទាំងអស់សម្រាប់ខ្លួនដាក់ទឹកដោះថ្លាពេញ អុជប្រឆេះចង្កៀងមួយពាន់ដួងជុំវិញៗ កណ្ដាប់មាត់ភាជន៍សំរិតនោះ យកសំពត់ចាស់ដែលជាខាងលើគ្របទុកត្រង់កណ្ដាល ឱ្យអុជភ្លើងដាក់លើភាជនៈសំរិតដើរវិលជុំវិញចេតិយប្រមាណ ១ យោជន៍ អស់មួយយប់ទល់ភ្លឺ ។ គេធ្វើកល្យាណកម្មរហូតអស់ជីវិត ដោយអត្តភាពសូម្បីនោះ

ដោយអាការយ៉ាងនេះ ហើយកើតក្នុងទេវលោក ។

កាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើង ។ គេចាប់បដិសន្ធិក្នុងផ្ទះរបស់ត្រកូលក្រខ្សត់ ក្នុងនគរនោះឯងទៀត ជាអ្នករែកស្មៅ នៅអាស្រ័យសុមនសេដ្ឋី គេបានមានឈ្មោះថា អន្នភារៈ ។ ចំណែកសុមនៈសេដ្ឋីនោះ ឱ្យមហាទានជិតទ្វារផ្ទះដល់មនុស្សកំព្រា អ្នកធ្វើដំណើរវណិពក និងយាចករាល់ថ្ងៃៗ ។

ក្រោយមកថ្ងៃមួយ ព្រះបច្ចេកពុទ្ធ នាមថា ឧបរិដ្ឋៈចូលនិរោធសម្បត្តិ លើភ្នំគន្ធមាទន៍ ចេញចាកសមាបត្តិនោះហើយពិចារណាថា ថ្ងៃនេះ គួរនឹងធ្វើការអនុគ្រោះអ្នកណា ។ ក៏ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ រមែងជាអ្នកអនុគ្រោះអ្នកក្រខ្សត់ លោកគិតថា ថ្ងៃនេះយើងគួរធ្វើការអនុគ្រោះ អន្នភារៈ ជ្រាបថា អន្នភារៈនឹងចេញចាកព្រៃមកកាន់ផ្ទះខ្លួន ទើបកាន់បាត្រនិងចីវរអំពីភ្នំគន្ធ-មាទន៍ ហោះឡើងកាន់វេហាស មកប្រាកដចំពោះមុខអន្នភារៈជិតទ្វារផ្ទះនុ៎ះឯង។ អន្នភារៈ ឃើញព្រះបច្ចេកពុទ្ធកាន់បាត្រទទេ ទើបថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយសួរថា លោកម្ចាស់ បានភិក្ខាខ្លះទេ ។ ព្រះបច្ចេកពុទ្ធល្ងេថា នឹងបាន អ្នកមានបុណ្យច្រើន ។ គេពោលថា លោកម្ចាស់ និមន្តរង់ចាំនៅទីនេះសិនចុះ ហើយប្រញាប់ទៅ សួរមាតុគ្រាមក្នុងផ្ទះរបស់ខ្លួនថា នាងដ៏ចម្រើនភត្តដែលជាចំណែករក្សាទុកដើម្បីយើង មានឬទេ? ។ នាងឆ្លើយថា បពិត្រស្វាមី ភត្ត

មាន ។ គេទៅអំពីទីនោះ ទទួលបាត្រអំពីដៃព្រះបច្ចេកពុទ្ធមក ពោលថា នាងដ៏ចម្រើន ព្រោះតែមិនបានធ្វើកល្យាណកម្មទុកក្នុងជាតិមុន ទើបយើងទាំង ២ ប្រាថ្នាបាននៅតែការទទួលឈ្នួល កាលសេចក្ដីប្រាថ្នានឹងឱ្យរបស់ពួកយើងមាន តែទេយ្យធម៌មិនមាន កាលទេយ្យធម៌មានក៏មិនបានបដិគ្គាហក: ថ្ងៃនេះយើងជួបព្រះឧបរិដ្ឋបច្ចេកពុទ្ធល្មម និងភត្តដែលជាចំណែករបស់ខ្លួនក៏មាន នាងចូរដាក់ភត្តដែលជាចំណែករបស់ខ្ញុំចុះក្នុងបាត្រនេះ ។ ស្រីដែលឈ្លាសគិតថា កាលណាស្វាមីរបស់យើងឱ្យភត្តដែលជាចំណែកបែងចែក កាលនោះសូម្បីយើង ក៏គប្បីមានចំណែកក្នុងទាននេះ ទើបដាក់សូម្បីភត្តដែលជាចំណែករបស់ខ្លួនចុះ ក្នុងបាត្រថ្វាយដល់ឧបរិដ្ឋបច្ចេកពុទ្ធ ។ អន្នភារៈ នាំបាត្រដែលប្ញុះភត្តមកដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធហើយល្វេថា សូមឱ្យពួកខ្ញុំផុតពីសេចក្ដីនៅយ៉ាងលំបាក បែបនេះចុះ លោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ អ្នកមានបុណ្យច្រើន ។ គេក្រាលសំពត់ដណ្ដប់របស់ខ្លួន ក្នុងទីមួយហើយ ពោលថា សូមអង្គុយឆាន់នៅទីនេះចុះ លោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធអង្គុយក្នុងអាសនៈនោះហើយ ពិចារណាសេចក្ដីជារបស់បដិកូល ៩ យ៉ាងហើយទើបឆាន់ កាលឆាន់រួចស្រេចហើយ អន្នភារៈ ទើបថ្វាយទឹកសម្រាប់លាងបាត្រ ព្រះបច្ចេកពុទ្ធសម្រេចភត្តកិច្ចហើយធ្វើ

អនុមោទនាថា:

សេចក្តីប្រាថ្នា ដែលអ្នកត្រូវការហើយ ចូរសម្រេចឱ្យបាន ឆាប់រួសរាន់ទាន់ចិត្ត, សេចក្តីត្រិះគ្រប់យ៉ាង ចូរពេញដល់អ្នក ដូចព្រះចន្ទពេញវង់ ក្នុងថ្ងៃ ១៥ កើត, ពុំនោះសោត ដូចមណីមានរស្មីដ៏រុងរឿង ជាកែវវិសេសអាចញុំាងសេចក្តីប្រាថ្នាទាំងពួងឱ្យសម្រេចបាន ដូច្នោះ ។

ហើយចេញធ្វើដំណើរទៅ ។

ទេវតាដែលស្ថិតនៅត្រង់ឆត្ររបស់សុមនសេដ្ឋីពោលថា គួរអស្ចារ្យ ទានដែលតាំងទុកល្អហើយ ក្នុងព្រះបច្ចេកពុទ្ធនាមថាឧបរិដ្ឋ: ជាទានយ៉ាងក្រៃលែង ៣ ដង, ហើយបានឱ្យសាធុការ ។

សុមនសេដ្ឋីល្ងៃថា លោកមិនឃើញយើង ឱ្យទានអស់រយៈកាល ប្រមាណប៉ុណ្ណោះទេឬ ?

ទេវតាល្ងៃថា យើងមិនឱ្យសាធុការក្នុងទានរបស់លោក យើងជ្រះថ្លាក្នុងបិណ្ឌបាត ដែលអន្នភារមាណពថ្វាយចំពោះព្រះបច្ចេកពុទ្ធ នាមថាឧបរិដ្ឋ: ទើបឱ្យសាធុការ ។

សុមនសេដ្ឋីត្រិះរិះថា រឿងនេះគួរអស្ចារ្យណាស់ យើងឱ្យទានអស់រយៈកាលប្រមាណប៉ុណ្ណោះ ក៏មិនអាចធ្វើឱ្យទេវតាឱ្យសាធុការ អន្នភារមាណព នេះ នៅអាស្រ័យយើង ដោយការថ្វាយបិណ្ឌបាតម្តងប៉ុណ្ណោះ ធ្វើឱ្យទេវតាឱ្យសាធុការបាន ព្រោះបាន

បុគ្គលដែលជាបដិគ្គាហកៈដ៏សមគួរ យើងឱ្យវត្ថុដែលសមគួរដល់អន្នភារមាណពនោះ ហើយធ្វើបិណ្ឌបាតនោះឱ្យជារបស់យើងទើបគួរ ដូច្នេះ ហៅអន្នភារមាណពមកហើយសួរថា ថ្ងៃនេះអ្នកឱ្យទានអ្វីៗ ដល់អ្នកណាឬ ?

បាទ លោកនាយ ខ្ញុំបានថ្វាយភត្តដែលជាចំណែករបស់ខ្ញុំដល់ព្រះបច្ចេកពុទ្ធនាមថាឧបរិដ្ឋៈ

សេដ្ឋីពោលថា ណ្ហើយចុះ អ្នកចូរទទួលកហាបណៈទៅហើយឱ្យបិណ្ឌបាតនោះដល់យើង

"ឱ្យមិនបានទេ លោកនាយ"

សេដ្ឋីបន្ថែមទ្រព្យឡើងដរាបដល់មួយឃ្នន់កហាបណៈ អន្នភារមាណព ក៏នៅតែល្ងេថា សូម្បីដល់មួយឃ្នន់កហាបណៈក៏នៅតែឱ្យមិនបាន សេដ្ឋីពោលថា ណ្ហើយចុះ បើអ្នកមិនឱ្យបិណ្ឌបាត ក៏ចូរទទួលទ្រព្យពាន់កហាបណៈទៅ ហើយឱ្យចំណែកបុណ្យដល់ខ្ញុំចុះ អន្នភារមាណពល្ងេថា ខ្ញុំមិនជ្រាបថា សូម្បីចំណែកបុណ្យនោះគួរឱ្យ ឬមិនគួរឱ្យទេ, តែខ្ញុំនឹងសួរព្រះបច្ចេកពុទ្ធនាមថាឧបរិដ្ឋៈសិន បើគួរឱ្យក៏នឹងឱ្យ បើមិនគួរឱ្យក៏នឹងមិនឱ្យ អន្នភារមាណពដើរទៅទាន់ព្រះបច្ចេកពុទ្ធ សួរថា លោកម្ចាស់ សុមនសេដ្ឋីឱ្យទ្រព្យដល់ខ្ញុំមួយពាន់ សូមចំណែកបុណ្យក្នុងបិណ្ឌបាត ដែលថ្វាយដល់លោកម្ចាស់ តើខ្ញុំគួរឱ្យឬមិនឱ្យ? ព្រះបច្ចេកពុទ្ធល្ងេថា បណ្ឌិត

អាត្មានឹងធ្វើឧបមាដល់អ្នក ដូចក្នុងស្រុកតំបន់នេះមានមួយរយត្រកូល យើងអុជប្រទីបទុកក្នុងផ្ទះមួយប៉ុណ្ណោះ ត្រកូលទាំងនេះយកប្រេងថែម ឱ្យប្រឆេះចង្កៀងដោតហើយមកអុជភ្លើងតកាន់ទៅពន្លឺរបស់ប្រទីបពីដើមនៅមានឬទេ ? អន្នភារមាណពល្ងើថា លោកម្ចាស់ ពន្លឺប្រទីបក៏ភ្លឺឡើងទៅទៀត សេចក្ដីនេះឧបមាយ៉ាងណា ម្នាលបណ្ឌិត យាគូមួយបោយ ឬបាយវែកមួយចូរលើកទុក កាលលោកឱ្យចំណែកបុណ្យដល់អ្នក ពួកដទៃក្នុងបិណ្ឌបាតរបស់ខ្លួន មួយទ្រនាក់ឬសែនអ្នកក៏ដោយ ឱ្យដល់អ្នកប៉ុនណា បុណ្យក៏បន្ថែមឡើងដល់ខ្លួន មានប្រមាណប៉ុណ្ណោះ កាលលោកឱ្យក៏ឱ្យបិណ្ឌបាតតែមួយនុំះឯង តែកាលឱ្យចំណែកបុណ្យដល់សុមនសេដ្ឋីទៀត បិណ្ឌបាតក៏ពង្រីកទៅជា ២ គឺរបស់លោកមួយចំណែករបស់សេដ្ឋីមួយចំណែក ដូច្នោះ អន្នភារមាណព ថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយ ត្រឡប់ទៅកាន់សំណាក់របស់សុមនសេដ្ឋីពោលថា សូមលោកទទួលចំណែក បុណ្យក្នុងបិណ្ឌបាតទានចុះ លោកនាយ សេដ្ឋីពោលថា អញ្ជើញអ្នកទទួលទ្រព្យមួយពាន់កហាបណៈទៅចុះ អន្នភារមាណពល្ងើថា ខ្ញុំមិនបានលក់បិណ្ឌបាតទាន តែខ្ញុំឱ្យចំណែកបុណ្យដល់លោកដោយសទ្ធា សេដ្ឋីល្ងើថា អន្នភារៈ អ្នកឱ្យចំណែកបុណ្យដល់យើងដោយសទ្ធា តែយើងបូជាគុណរបស់អ្នក ខ្ញុំឱ្យពាន់កហាបណៈនេះ ចូរទទួលទៅចុះ អន្នភារៈ អន្នភារ

មាណពពោលថា ចូរជាយ៉ាងនោះ ទើបកាន់យកទ្រព្យមួយពាន់កហាបណៈទៅ សេដ្ឋីល្ងេថា អន្នភារៈតាំងពីល្មមបានទ្រព្យពាន់កហាបណៈហើយ មិនត្រូវធ្វើកិច្ចជាកម្មករដោយដៃរបស់ខ្លួន, ចូរសាងផ្ទះនៅជិតថ្នល់ចុះ បើអ្នកត្រូវការវត្ថុណា ខ្ញុំនឹងប្រគល់វត្ថុនោះឱ្យ អ្នកចូរមកនាំយកទៅចុះ

ធម្មតាបិណ្ឌបាត ដែលបុគ្គលថ្វាយចំពោះព្រះបច្ចេកពុទ្ធអ្នកចេញចាកនិរោធសមាបត្តិ រមែងឱ្យផលក្នុងថ្ងៃនោះឯង ព្រោះដូច្នោះ សុមនសេដ្ឋីក្នុងថ្ងៃដទៃសូម្បីទៅកាន់រាជត្រកូល មិនធ្លាប់បបួលអន្នភារមាណពទៅផង តែក្នុងថ្ងៃនោះ បានបបួលទៅផង ព្រោះអាស្រ័យបុណ្យរបស់អន្នភារមាណព ព្រះរាជាមិនសម្លឹងមើលសេដ្ឋីឡើយ ទ្រង់មើលតែអន្នភារមាណពប៉ុណ្ណោះ សេដ្ឋីទើបទូលសួរថា ទេវបពិត្រសម្មតិទេព ហេតុដូចម្ដេច បានជាព្រះអង្គទ្រង់សម្លឹងមើលតែបុរស អ្នកនេះក្រៃលែងណាស់ក្រាបទូល ព្រះរាជាត្រាស់ថា យើងសម្លឹងមើល ព្រោះមិនធ្លាប់គាល់ក្នុងថ្ងៃដទៃៗ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព គេសមគួរសម្លឹងមើលយ៉ាងណា? គុណដែលគួរសម្លឹងមើលរបស់គេ គឺអ្វី ព្រោះថ្ងៃនេះគេមិនបរិភោគភត្តដែលជាចំណែករបស់ខ្លួនដោយខ្លួនឯង តែថ្វាយចំពោះព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈ គេបានទ្រព្យន្ទ់កហាបណៈអំពីដៃ របស់ខ្ញុំព្រះអង្គព្រះអង្គ ព្រះរាជាត្រាស់សួរថា គេឈ្មោះអ្វី?

ឈ្មោះអន្នភារៈ ក្រាបទូល ព្រោះបានអំពីដៃរបស់លោក ក៏គួរនឹងបានអំពីដៃរបស់យើងខ្លះ យើងក៏នឹងធ្វើការបូជាគេ ទើបព្រះរាជទានទ្រព្យមួយពាន់កហាបណៈហើយត្រាស់ថា អ្នកចូរត្រួតមើលផ្ទះដែលអ្នកនេះនឹងនៅ រាជបុរសទូលថា ករុណាថ្លៃវិសេស រាជបុរសទាំងឡាយចាត់ចែង បោសប្រាសសម្អាតទីសម្រាប់ផ្ទះនោះ បានជួបរណ្តៅទ្រព្យឈ្មោះ បិង្គលៈ ក្នុងទីដែលចាបប៉ះខ្ទប់ហើយៗ តាំងរៀងគ្នា ទើបមកក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាប, ព្រះរាជាត្រាស់ថា បើយ៉ាងនោះចូរទៅជីកឡើងមក កាលរាជបុរសទាំងនោះជីកនៅ រណ្តៅទ្រព្យក៏លិចចុះទៅ រាជបុរសទាំងនោះទៅក្រាបទូលព្រះរាជាទៀត ព្រះរាជាត្រាស់ថា ចូរទៅជីកតាមពាក្យរបស់អន្នភារមាណព រាជបុរសក៏ទៅជីកតាមពាក្យបង្គាប់ រណ្តៅទ្រព្យដូចផ្កាផ្សិតក្រពុំៗ ផុសឡើងក្នុងទីចាប់ប៉ះខ្ទប់ហើយ រាជបុរសទាំងនោះជញ្ជូនទ្រព្យមកគរទុកក្នុងព្រះរាជសំណាក់ ព្រះរាជាប្រជុំអាមាត្យទាំងឡាយហើយត្រាស់សួរថា ក្នុងក្រុងនេះអ្នកណាមានទ្រព្យប្រមាណដល់ប៉ុណ្ណោះទេ អាមាត្យទូលថា មិនមានអ្នកណាមានទេ ក្រាបទូល ត្រាស់ថា បើយ៉ាងនោះ អន្នភារមាណពនេះចូរឈ្មោះថា ធនសេដ្ឋីក្នុងព្រះនគរនេះ គេបានឆត្រប្រចាំតំណែងសេដ្ឋីក្នុងថ្ងៃនោះឯង ។

តាំងពីថ្ងៃនោះ គេធ្វើតែកម្មដែលល្អដរាបអស់ជីវិត ចុតិអំពី

ភាពនោះទៅ កើតក្នុងទេវលោក រិលវល់នៅក្នុងទេវតា និងមនុស្ស ជាវេលាយូរ គ្រាដែលព្រះសាស្តារបស់ពួកយើងទ្រង់ឧប្បត្តិ ក៏មកចាប់បដិសន្ធិក្នុងនិវេសន៍ ស្តេចសក្យៈព្រះនាមថា អមិតោទនៈ ក្រុងកបិលភស្តុក្នុងថ្ងៃតាំងនាម មនុស្សទាំងឡាយតាំងឈ្មោះគេថា អនុរុទ្ធ ជាកនិដ្ឋភាតរបស់ស្តេចសក្យៈព្រះនាមថា មហានាមៈ ជាឱរសរបស់ស្តេចមានៃព្រះសាស្តា ជាសុខុមាលជាតិយ៉ាងក្រៃលែង ជាអ្នកមានបុណ្យច្រើន កត្តរកើតឡើងក្នុងថាសមាសដល់គេនោះឯង ខាងក្រោយព្រះមាតារបស់គេគិតថា នឹងឱ្យកូនរបស់យើងស្គាល់ពាក្យថា មិនមាន យកថាសមាសបិទថាសមាសមួយទៀត ហើយបញ្ជូនតែថាសទទេៗ ក្នុងចន្លោះផ្លូវ ទេវតាធ្វើឱ្យពេញដោយនំទិព្វ គេមានបុណ្យច្រើនដល់ត្រឹមនេះ ដែលពួកនាងរបាំដែលប្រដាប់តាក់តែងហើយហែហមសោយសម្បត្តិលើប្រាសាទ ៣ ខ្នងសមគួរដល់រដូវទាំង ៣ ដូចទេវតា ។

ចំណែកព្រះពោធិសត្វរបស់យើង ចុតិអំពីតុសិតក្នុងសម័យនោះ មកចាប់បដិសន្ធិក្នុងគភ៌របស់អគ្គមហេសីនៃព្រះបាទសុទ្ធោទនមហារាជ ទ្រង់ចម្រើនវ័យដោយលំដាប់ ទ្រង់គ្រប់គ្រងផ្ទះនៅ ២៩ ឆ្នាំ ហើយទ្រង់ស្តេចចេញមហាភិនេស្រ្កមណ៍ ទ្រង់ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ទ្រង់សម្ងំជិតធ្មេមិណ្ឌស្ថាន ៧ សប្តាហ៍ ប្រកាសព្រះធម្មចក្រក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់

ធ្វើការអនុគ្រោះលោក ទ្រង់ឱ្យអាមាត្យ ១០ នាក់ ព្រមទាំងបរិវារ ម្នាក់មួយពាន់ៗ ដែលព្រះរាជបិតាទ្រង់ស្តាប់ដំណឹងថា បុត្ររបស់យើងមកកាន់ក្រុងរាជគ្រឹះហើយ ត្រាស់ថា អ្នកទាំងឡាយ ទៅចុះពួកអ្នកចូរនាំបុត្ររបស់យើងមក ដូច្នេះ ឱ្យបួសដោយឯហិភិក្ខុបព្វជ្ជាហើយ ដែលព្រះកាឡុទាយីត្ថេរទូលអង្វរឱ្យ ស្តេចចារិកទើបមានភិក្ខុសែនរូបជាបរិវារ ស្តេចចេញពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងកបិលភស្តុ ទ្រង់ធ្វើព្រះធម៌ទេសនាដ៏វិចិត្រមានបាដិហារ្យ ដោយឥទ្ធិបាដិហារ្យជាច្រើន ក្នុងសមាគមនៃព្រះញាតិ ញុំាំងមហាជនឱ្យផឹកទឹកអម្រឹតហើយ គ្រាថ្ងៃទី ២ ទ្រង់កាន់បាត្រ និងចីវរទៅប្រថាប់ឈរត្រង់ទ្វារព្រះនគរ ទ្រង់រំពឹងថា ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គទ្រង់ប្រព្រឹត្តការស្តេចត្រឡប់ចូលកាន់ព្រះនគរ នៃត្រកូលដូចម្តេច ដូច្នេះជ្រាបថា ទ្រង់ប្រព្រឹត្តត្រាច់បិណ្ឌបាតតាមលំដាប់ច្រកផ្លូវ ទើបទ្រង់ស្តេចដើម្បីបិណ្ឌបាតតាមលំដាប់ច្រកផ្លូវ ទ្រង់ត្រាស់ធម៌ថ្វាយព្រះរាជា អ្នកទ្រង់ស្តាប់ដំណឹងថា បុត្ររបស់យើងត្រាច់បិណ្ឌបាត ស្តេចមកហើយ, ព្រះមានព្រះភាគដែលព្រះរាជបិតា ទូលអារាធនាឱ្យស្តេចមកហើយ ទូលអារាធនាឱ្យស្តេចចូលនិវេសន៍របស់ព្រះអង្គ ទ្រង់ធ្វើសក្ការៈសម្មានះហើយ ទើបទ្រង់អនុគ្រោះព្រះញាតិដែលគួរអនុគ្រោះក្នុងទីនោះ ហើយឱ្យរាហុលកុមារបព្វជ្ជាហើយ មិនយូរប៉ុន្មាន ក៏យាងចេញពីក្រុងកបិលភស្តុ

ចារិកទៅក្នុងមល្លរដ្ឋហើយស្តេចត្រឡប់មកកាន់ អនុបិយអម្ពវ័ន ។

សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ប្រជុំសក្យៈត្រកូលទាំងឡាយ ត្រាស់ថា បើបុត្ររបស់យើងគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយរតនៈ ៧ សូម្បីរាហុលកុមារនត្តារបស់យើង នឹងហែហមស្តេចចក្រពត្តិនោះត្រាច់ទៅនឹងពួកក្សត្រិយ៍ មួយទៀត សូមឱ្យពួកលោកទាំងឡាយ ជ្រាបសេចក្តីនេះទុកចុះថា តែឥឡូវនេះ បុត្ររបស់យើងទ្រង់ជាព្រះពុទ្ធហើយ ខត្តិយកុមារចូរជាបរិវាររបស់ព្រះអង្គចុះ ពួកលោកចូរឱ្យទារកម្នាក់អំពីត្រកូលមួយៗ គ្រាព្រះបាទសុទ្ធោទន ត្រាស់យ៉ាងនេះហើយ ទើបខត្តិយកុមារមួយន់អង្គ ចេញបួសដោយព្រះតម្រាស់គ្រាតែមួយប៉ុណ្ណោះ សម័យនោះស្តេចមហានាម ជាម្ចាស់នៃកុដុម្ពី ទើបចូលទៅរកស្តេចសក្យៈព្រះនាមថា អនុរុទ្ធៈបានពោលពាក្យនេះថា អនុរុទ្ធៈ ឥឡូវនេះ សក្យៈកុមារដែលមានកេរ្តិ៍ឈ្មោះ ចេញបួសតាមព្រះមានព្រះភាគដែលទ្រង់បួសហើយ មិនទាន់មានអ្នកណាៗអំពីត្រកូលរបស់យើងឡើយ, បើដូច្នោះ ប្អូនឯងចូរបួស ឬថាបងនឹងបួស ស្តេចអនុរុទ្ធបានស្តាប់តម្រាស់របស់ម្ចាស់បងហើយ មិនត្រេកអរក្នុងការគ្រប់គ្រងផ្ទះបានចេញព្រះផ្នួសជាព្រះអង្គទី ៧ លំដាប់នៃការព្រះផ្នួសរបស់ព្រះអនុរុទ្ធនោះ មកហើយក្នុងគម្ពីរសង្ឃភេទក្ខន្ធកៈ ព្រះអនុរុទ្ធទៅកាន់អនុបិយអម្ពវ័ន បួសហើយដោយប្រការ

ដូច្នេះ បណ្ដាស្ដេចសក្យៈកុមារទាំងនោះព្រះភទ្ទិយត្ថេរសម្រេចព្រះអរហត្តខាងក្នុងវស្សានុ៎ះឯង, ព្រះអនុរុទ្ធត្ថេរធ្វើទិព្វចក្ខុឱ្យកើត, ព្រះទេវទត្តធ្វើសមាបត្តិ ៨ ឱ្យកើត, ព្រះអានន្ទត្ថេរតាំងនៅក្នុងសោតាបត្តិផល ខាងក្នុងវស្សានុ៎ះឯង, ព្រះភគ្គុត្ថេរនិងព្រះកិមភិលត្ថេរ បានសម្រេចអរហត្តក្នុងខាងក្រោយ ក៏អភិនិហារនៃសេចក្ដីប្រាថ្នា អំពីកាលមុនរបស់ព្រះថេរៈគ្រប់រូបនោះ នឹងមកដល់ក្នុងរឿងមួយអង្គៗ ។

ក៏ព្រះអនុរុទ្ធត្ថេរនេះ រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះធម្មសេនាបតី ហើយទៅបំពេញសមណធម៌បាចីនវង្សទាយវ័នដែនចេតិយៈក៏ត្រិះរិះហើយដល់មហាបរិវិតក្ក ៧ ប្រការ លំបាកក្នុងវិតក្កទី ៨ ព្រះសាស្ដាទ្រង់ជ្រាបថាព្រះអនុរុទ្ធលំបាកក្នុងរកបុរិសវិតក្កទី ៨ ទ្រង់ព្រះតម្រិះថា យើងនឹងធ្វើសេចក្ដីត្រិះរិះរបស់លោកឱ្យពេញ ទើបស្ដេចទៅក្នុងទីនោះ គង់នៅលើពុទ្ធអាសនៈដ៏ប្រសើរដែលគេក្រាលទុក ទ្រង់ធ្វើមហាបុរិសវិតក្កទី ៨ ឱ្យពេញ ហើយត្រាស់មហាអរិយវង្សបដិបទា ប្រដាប់ទៅដោយសេចក្ដីសន្ដោសដោយបច្ច័យ ៤ និងមានភាវនាជាដែលមកត្រេកអរហើយស្ដេចហោះទៅដល់ភេសកឡាវ័ន ។

លុះព្រះតថាគតស្ដេច ទៅហើយប៉ុណ្ណោះព្រះថេរៈ មានវិជ្ជា ៣ ជាព្រះមហាខីណាស្រពធំ គិតថា ព្រះសាស្ដាដឹងចិត្តរបស់

យើង ស្តេចមកប្រទានមហាបុរិសវិតក្កដែល ៨ ឱ្យពេញ ។ មួយទៀត មនោរថរបស់យើងនោះដល់ទីបំផុតហើយ ប្រារព្ធធម៌ទេសនាដ៏ពីរោះ របស់ព្រះពុទ្ធទាំងឡាយ និងធម៌ដែលខ្លួនត្រាស់ដឹងហើយ បានភាសិតឧទានគាថាទាំងនេះថា:

ព្រះសាស្តាទ្រង់ជាអគ្គបុគ្គលក្នុងលោក ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់យើង ហើយស្តេចមករកយើងដោយមនោមយិទ្ធិផ្លូវកាយ កាលណាសេចក្តី ត្រិះរិះបានមានដល់យើង កាលនោះព្រះពុទ្ធទ្រង់សម្តែងធម៌ឱ្យខ្ពស់ឡើង ព្រះពុទ្ធអ្នកទ្រង់ត្រេកអរក្នុងធម៌គ្រឿងមិនយឺតយូរ បានទ្រង់សម្តែងធម៌គ្រឿងមិនយឺតយូរ យើងដឹងទូទៅដល់ធម៌របស់ព្រះអង្គហើយ ជាអ្នកត្រេកអរក្នុងព្រះសាសនានៅ វិជ្ជា ៣ យើងក៏សម្រេចដោយលំដាប់ហើយ ក្យប្រៀនប្រដៅរបស់ព្រះពុទ្ធយើងក៏ធ្វើសម្រេចហើយ ដូច្នេះ ។

តមកខាងក្រោយ ព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហា-វិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈថា អនុរុទ្ធៈជាកំពូលរបស់ពួកភិក្ខុសាវក អ្នកមានទិព្វចក្ខុក្នុងសាសនារបស់យើង ។

## ព្រះគាថាអនុមោទនា

នៅក្នុងភេសជ្ជក្ខន្ធកៈ ព្រះត្រៃបិដកលេខ ៧ ទំព័រ ៣០៩ មានសម្តែងរឿងមហាអាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ

និងវស្សការៈ នាំគ្នាចូលទៅគាល់ព្រះអង្គ សូមអារាធនាព្រះអង្គ ព្រមទាំងភិក្ខុសង្ឃដើម្បីទទួលភត្តក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ក៏បានទទួល លុះស្អែកឡើងសុនីធៈ និងវស្សការៈមហាមាត្យ ក៏អង្គាសព្រះភិក្ខុសង្ឃដែលមានព្រះមានព្រះភាគជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ត្រាតែភិក្ខុសង្ឃហាមឃាត់ ឯព្រះមានព្រះភាគក៏ទ្រង់លែងលូកព្រះហស្តចូលទៅក្នុងបាត្រ ចំណែកមហាមាត្យទាំងពីរក៏អង្គុយក្នុងទីសមគួរ ។ គ្រានោះព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនាដោយព្រះគាថាទាំងនេះថា៖

យស្មឹ បទេសេ កប្បេតិ វាសំ បណ្ឌិតជាតិយោ
សីលវន្តេត្ថ ភោជេត្វា សញ្ញោត ព្រហ្មចារិនោ
យា តត្ថ ទេវតា អាសុំ តាសំ ទក្ខិណមាទិសេ ។
តា បូជិតា បូជយន្តិ មានិតា មានយន្តិ នំ
តតោ នំ អនុកម្បន្តិ មាតា បុត្តំវ ឱរសំ។
ទេវតានុកម្បិតោបោសោ សទា ភទ្រានិ បស្សតីតិ ។

មនុស្សជាបណ្ឌិតជាតិរមែងសម្រេចនូវការនៅក្នុងប្រទេសណាហើយ ក៏តែងឱ្យពួកបុគ្គលអ្នកមានសីល ដែលសង្រួមល្អប្រព្រឹត្តធម៌ដ៏ប្រសើរ ឱ្យបរិភោគក្នុងលំនៅរបស់ខ្លួន ហើយបានទាំងឧទ្ទិសផលទក្ខិណាទាន (ឱ្យចំណែកបុណ្យ)ដល់ពួកទេវតាដែលនៅក្នុងប្រទេសនោះ (ថែមទៀត) ។ ទេវតាទាំងនោះ តែង

បូជាចំពោះមនុស្សដែលបានបូជាដល់ខ្លួន តែងរាប់អានចំពោះមនុស្សដែលរាប់អានដល់ខ្លួន តែងអនុគ្រោះមនុស្សនោះ ដូចជាមាតាអនុគ្រោះបុត្រដែលខ្លួនបីថ្នមផ្ទាប់នឹងទ្រូងឱ្យចម្រើនឡើង។ មនុស្សដែលទេវតាបានអនុគ្រោះហើយ ក៏តែងឃើញនូវសេចក្តីចម្រើនសព្វៗកាល ។

កាលព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនាដោយព្រះគាថាទាំងឡាយនេះ ចំពោះមហាអាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈ(ចប់ហើយ)ទ្រង់ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។

## តិរោកុឌ្ឌសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៥៦ ទំព័រ ៤៦ ព្រះអង្គទ្រង់ត្រាស់អំពី **ការឧទ្ទិសចំណែកបុណ្យដល់អ្នកដែលស្លាប់ទៅ** ដែលសេចក្តីថា៖

**តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច**
**ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វា សកំ ឃរំ ។**

ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិដោយគិតថា ផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ ។

**បហុតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ**

នាកាលបាយនិងទឹក និងបង្អែម និងចម្អាបដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ

**ន តេសំ កោចិ សរតិ សត្តានំ កម្មប្បច្ចយា ។**

ញាតិណាមួយមិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។

**ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា**

**សុចឹ បណីតំ កាលេន កប្បិយំ ចានភោជនំ**

ញាតិទាំងឡាយឯណា តែងអនុគ្រោះញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹកនិងភោជនដ៏ហ្មត់ចត់ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះទៅហើយនោះយ៉ាងនេះថា៖

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

ទាននេះ ចូលមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្ដីសុខ ។

**តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា**

ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ

**បហុតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ**

កាលបើថ្វាយបាយនិងទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនា

ដោយគោរពថា:

**ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុលភាមសេ**

*យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះរបស់យើងទាំងឡាយចូររស់នៅយឺនយូរ*

**អម្ហាកញ្ច កតា បូជា** *ក៏បូជាគឺញាតិទាំងឡាយ ធ្វើហើយដល់យើងទាំងឡាយ*

**ទាយកា ច អនិប្ផលា** *ឯទាយកគឺអ្នកឱ្យទាន ក៏មិនឥតផល*

**ន ហិ តត្ថ កសី អត្ថិ** *កសិកម្ម គឺការភ្ជួរស្រែចម្ការ ក៏មិនមានក្នុងភូមិនៃប្រេតនោះ*

**គោរក្ខេត្ថ ន វិជ្ជតិ** *គោរក្ខកម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ*

**វណិជ្ជា តាទិសី នត្ថិ** *ពាណិជ្ជកម្ម គឺការជួញ ដែលជាហេតុបានសម្បត្តិដូច្នោះក៏មិនមាន*

**ហិរញ្ញេន កយាកយំ** *មិនមានការលក់ទិញផ្លាស់ប្តូរដោយប្រាក់ ។*

**ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ**

*បុគ្គលទាំងឡាយធ្វើកាលកិរិយាទៅកើតជាប្រេត រមែង*

ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិឱ្យហើយអំពីលោកនេះ

**ឧន្នតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ**

**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ។**

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាបដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ**

**ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេនិងស្ទឹងជាដើម រមែងញុំាងសាគរឱ្យពេញព្រៀបដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

**អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ**

**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។**

បុគ្គលកាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត និងជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឱ្យទក្ខិណាទាន

ដើម្បីប្រេតទាំងឡាយ ។

ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា

ការយំឬសោកសៅ ឬការខ្សឹកខ្សួលដទៃៗ មិនមានប្រយោជន៍ឡើយ

ន តំ បេតា នមត្ថាយ ធ្វើដូច្នោះរកបានជាប្រយោជន៍ដល់ប្រេតទាំងឡាយគ្មាន

ឯវំ តិដ្ឋន្តិ ញាតយោ ញាតិទាំងឡាយរមែងស្ថិតនៅឥតបានដឹង បានឮយ៉ាងនេះ។

អយញ្ច ខោ ទក្ខិណា ទិន្នា បើទក្ខិណាទានដែលបុគ្គលបានឱ្យហើយនេះឯង

សង្ឃម្ហិ សុបតិដ្ឋិតា ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ

ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ។

ទក្ខិណាទាននោះ ទើបចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។

សោ ញាតិធម្មោ ច អយំ និទស្សិតោ ក៏ញាតិធម៌នោះគឺអ្នកបានសម្តែងជាបែបយ៉ាងហើយ

បេតាន បូជា ច កតា ឧឡារា ការបូជាដ៏ថ្លៃថ្លាចំពោះដល់ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ

ពលញ្ច ភិក្ខូនមនុប្បទិន្នំ កម្លាំងកាយនៃភិក្ខុទាំងឡាយ

ឈ្មោះថា គឺអ្នកបានបំពេញឱ្យហើយ

**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ** បុណ្យ គឺអ្នកសន្សំទុកហើយ មិនមែនតិចដូច្នេះ ។ (លំនាំសូត្រតាមភាណវារៈ)

## អដ្ឋកថា

## និក្ខេបប្បយោជនំ

### ប្រយោជន៍នៃការតាំងព្រះសូត្រ

ឥឡូវនេះដល់លំដាប់ការពណ៌នាសេចក្ដីនៃតិរោកុឌ្ឌសូត្រ ដែលកើតឡើងជាលំដាប់អំពីរតនសូត្រដោយន័យថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើមនឹងពោលប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនោះទុកក្នុងទីនេះហើយ ទើបពណ៌នាសេចក្ដី ។

ក្នុងសេចក្ដីនោះ ការពិតតិរោកុឌ្ឌសូត្រនេះ សូម្បីព្រះមានព្រះភាគ ក៏មិនត្រាស់តាមលំដាប់នេះ ប៉ុន្តែក៏ទ្រង់សម្ដែងការបដិបត្តិកុសលកម្មនេះបានដោយប្រការផ្សេងៗទុកមុនព្រះសូត្រនេះ ព្រោះហេតុដែលបុគ្គលប្រមាទក្នុងការបដិបត្តិកុសលកម្មនោះ កាលកើតក្នុងឋានៈ ដែលរមែងសោកសៅជាងនរកហើយនឹងកំណាត់សត្វតិរច្ឆាន ក៏រមែងកើតក្នុងប្រេតវិស័យប្រាកដដូចនោះ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់រតនសូត្រ ដើម្បីសម្ដែងថា បុគ្គលមិនគួរធ្វើសេចក្ដីប្រមាទ ក្នុងការបដិបត្តិកុសលកម្មនោះ ហើយដើម្បីរម្ងាប់ឧបទ្រពនៃក្រុងវេសាលី ដែលពួកភូតឯណា

បានបៀតបៀនហើយ ឬត្រាស់ដើម្បីសម្តែងថា បណ្តាភូតទាំង អស់នោះ មានភូតពួកខ្លះ មានរូបប្រាកដដូច្នោះ គប្បីជ្រាប ប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនេះក្នុងទីនេះ ។

## អនុមោទនាគាថា

គាថាអនុមោទនា ក៏ការពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រ មានដូច្នេះ ព្រោះហេតុតែតិរោកុឌ្ឌសូត្រ អ្នកណាប្រកាស, ប្រកាស ក្នុងទីណា ប្រកាសពីកាលណា ហើយប្រកាសព្រោះហេតុអ្វី ការ ពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនោះទាំងអស់ហើយ កាលធ្វើ តាមលំដាប់ឈ្មោះថា ធ្វើល្អហើយដូច្នោះ ខ្ញុំក៏នឹងធ្វើការពណ៌នា សេចក្តីនោះ យ៉ាងនោះដូចគ្នា ។

សេចក្តីថា ក៏តិរោកុឌ្ឌសូត្រនេះអ្នកណាប្រកាស ប្រកាស ក្នុងទីណាប្រកាសពេលណា ហើយប្រកាសព្រោះហេតុអ្វី ។ សេចក្តីពន្យល់ដូច្នេះ តិរោកុឌ្ឌសូត្រព្រះមានព្រះភាគទ្រង់ប្រកាស ក៏តិរោកុឌ្ឌសូត្រនោះ ទ្រង់ប្រកាសដើម្បីទ្រង់អនុមោទនា ចំពោះ ព្រះបាទមគធរដ្ឋក្នុងថ្ងៃព្រឹកឡើង ។ ដើម្បីធ្វើសេចក្តីនេះឱ្យជាក់ ច្បាស់ គួរពោលរឿងពិស្តារក្នុងតិរោកុឌ្ឌសូត្រ នោះដូចតទៅនេះ

ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ មាននគរឈ្មោះកាសី ។ ក្នុងនគរនោះមានព្រះរាជាព្រះនាមថា ជយសេន ព្រះទេវីរបស់ ព្រះរាជានោះព្រះនាមថា សិរិមា ព្រះពោធិសត្វព្រះនាមថាបុស្សៈ

កើតក្នុងគភ៌របស់ព្រះនាងត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញាណតាមលំដាប់ៗ ព្រះរាជាជយសេនទ្រង់កើតការរឭកដល់ភាវៈព្រះអង្គថា ឱរសរបស់យើងទ្រង់ចេញសាងផ្នួស ហើយត្រាស់ដឹងជាព្រះពុទ្ធ ព្រះពុទ្ធក៏ជារបស់យើង ព្រះធម៌ក៏ជារបស់យើង ព្រះសង្ឃក៏ជារបស់យើង ទ្រង់ឧបដ្ឋាកដោយព្រះអង្គឯង រហូតគ្រប់វេលា រមែងមិនប្រទានឱកាសដល់មនុស្សដទៃ ។

បងប្អូនរបស់ព្រះមានព្រះភាគ ព្រះមាតាផ្សេងៗគ្នាមាន ៣ ព្រះអង្គនាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងទ្រង់ឧប្បត្តិឡើងដើម្បីជាប្រយោជន៍ជួយដល់សត្វលោកទាំងពួង មិនមែនដើម្បីប្រយោជន៍ដល់បុគ្គលតែម្នាក់ តែព្រះបិតារបស់យើងមិនទ្រង់ប្រទានឱកាសដល់យើង និងមនុស្សដទៃៗឡើយ យើងនឹងបានការឧបដ្ឋាកយ៉ាងណាហ្ន៎ ។ ព្រះរាជឱរសពួកនោះ ទើបគិតយ៉ាងនេះថា ចាំយើងនឹងធ្វើឧបាយណាមួយ ។ ព្រះរាជបុត្រទាំង ៣ ព្រះអង្គទើបឱ្យមេស្រុក ជាយដែនធ្វើការប៉ះបោរៗ អំពីនោះ ព្រះរាជាទ្រង់ជ្រាបដំណឹងថា មេស្រុកជាយដែនប៉ះបោរ ទើបទ្រង់បញ្ជូនព្រះរាជឱរសទាំង ៣ ព្រះអង្គឱ្យចេញទៅបង្ក្រាប ។ ព្រះរាជឱរសទាំងនោះបង្ក្រាបស្រេចហើយ ក៏ស្ដេចត្រឡប់មកវិញ ព្រះរាជាទ្រង់រីករាយព្រះរាជហឫទ័យ ព្រះរាជាទើបប្រទានពរថា បុត្រប្រាថ្នាវត្ថុណា ក៏ចូរទទួលវត្ថុនោះ ។ ព្រះរាជឱរស

ទាំង ៣ ព្រះអង្គ ក្រាបទូលថា ខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកព្រះមានព្រះភាគ ព្រះរាជាត្រាស់ថា លើកលែងពរនោះចេញ ចូរបុត្រប្រាថ្នាពរផ្សេងទៀតចុះ ។ ព្រះរាជឱរសក្រាបទូលថា ពួកខ្ញុំព្រះអង្គមិនប្រាថ្នាពរដទៃឡើយ ។ ព្រះរាជាត្រាស់ថា ប្រសិនបើយ៉ាងនោះ បុត្រកំណត់វេលាមកហើយទទួលចុះ ។ ព្រះរាជឱរសទូលសុំ ៧ ឆ្នាំ ។ ព្រះរាជាមិនព្រះរាជទានឱ្យព្រះរាជឱរសទើបក្រាបទូលសុំថយចុះយ៉ាងនេះគឺ ៦-៥-៤-៣-២-១ ឆ្នាំ ៧-៦-៥-៤ខែ រហូតដល់ត្រឹម ៣ ខែ ព្រះរាជាទើបទ្រង់ព្រះរាជទានថាបើដូច្នោះ អ្នកចូរទទួលយកចុះ ។ ព្រះរាជឱរសទាំងនោះ បានទទួលពរហើយ ក៏ទ្រង់ត្រេកអរយ៉ាងក្រៃលែង ចូលគាល់ព្រះដ៏មានព្រះភាគថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនពួកខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាក ព្រះដ៏មានព្រះភាគគ្រប់ ៣ ខែសូមព្រះដ៏មានព្រះភាគទ្រង់ទទួលចាំវស្សា ៣ ខែ ដើម្បីជាប្រយោជន៍ដល់ខ្ញុំព្រះអង្គផងចុះ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព គឺអាការៈស្ងៀមៗ បន្ទាប់ពីនោះមកព្រះរាជឱរសទាំង ៣ ព្រះអង្គ ក៏ទ្រង់បញ្ជូនព្រះរាជសារ ឡាយព្រះហស្ដទៅប្រាប់ដល់រាជបុរសអ្នកនាំសួយសារអាករ ក្នុងជនបទរបស់ព្រះអង្គថា យើងនឹងបម្រើព្រះដ៏មានព្រះភាគអស់ ៣ខែនេះ អ្នកចូលរៀបចំសម្ភារៈ ប្រកបការទំនុកបម្រុងព្រះដ៏មាន

ព្រះភាគទុកឱ្យសព្វគ្រប់ផ្ដើមពីការកសាងព្រះវិហារជាដើម ។ អ្នកនាំសួយ អាករនោះ ចាត់ការសព្វគ្រប់យ៉ាងហើយ ក៏បញ្ជូនបញ្ជីរបាយការណ៍ឱ្យទ្រង់ជ្រាប។ ព្រះរាជឱរសទាំងនោះ ក៏ទ្រង់ស្លៀកដណ្ដប់សំពត់កាសាយៈ ទ្រង់ឧបដ្ឋាកព្រះដ៏មានព្រះភាគដោយគោរព ដោយបុរសជាវេយ្យាវច្ចករចំនួន ២,៩០០ នាក់នាំព្រះដ៏មានព្រះភាគឆ្ពោះទៅកាន់ជនបទ វេរថ្វាយព្រះវិហារឱ្យទ្រង់គង់ចាំព្រះវស្សា ។

គហបតិបុត្តម្នាក់ ជាអ្នករក្សាឃ្លាំងរបស់ព្រះរាជឱរសទាំងនោះ ព្រមទាំងភរិយា ជាបុគ្គលមានបសាទសទ្ធាបានចូលទៅបដិបត្តិថ្វាយទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដោយគោរព ។ អ្នកនាំសួយសារអាករជនបទ នាំគហបតិបុត្តនោះ ឱ្យដំណើរការថ្វាយទានដោយគោរព ព្រមដោយអ្នកស្រុកជនបទប្រមាណ ១១,០០០ នាក់ ។ បណ្ដាមនុស្សទាំងនោះ ជនពួកខ្លះមានចិត្តឥស្សាមច្ឆរិយៈគ្របសង្កត់ ពួកគេក៏នាំគ្នាធ្វើអន្តរាយដល់ទាន បរិភោគទេយ្យវត្ថុដោយខ្លួនឯងខ្លះ ឱ្យដល់ពួកកូនៗខ្លះ ហើយយកភ្លើងដុតសាលាទានខ្លះ។គ្រាបវារណាចេញព្រះវស្សា ព្រះរាជឱរសទាំងឡាយ ក៏ទ្រង់ធ្វើសក្ការៈយ៉ាងក្រៃលែង ចំពោះព្រះដ៏មានព្រះភាគ តាមព្រះដ៏មានព្រះភាគចូលទៅគាល់ព្រះរាជបិតា។ព្រះដ៏មានព្រះភាគស្ដេចទៅក្នុងទីនោះហើយក៏បរិនិព្វាន។

ព្រះរាជាផង ព្រះរាជឱរសផង អ្នកនាំសួយសារអាករក្នុងជនបទផង និងអ្នករក្សាឃ្លាំងផងធ្វើកាលកិរិយា ទៅជាបន្តបន្ទាប់ក៏កើតក្នុងស្ថានសួគ៌ព្រមដោយបរិស័ទជាបរិវារ ។ ចំណែកពួកជនដែលមានចិត្តឥស្សាមច្ឆរិយៈគ្របសង្កត់ ក៏ទៅកើតក្នុងស្ថាននរក បណ្ដាមនុស្សទាំង ២ ក្រុមនោះ មួយក្រុមស្លាប់ពីស្ថានសួគ៌ឱ្យទៅកើតស្ថាន សួគ៌ ចំណែកមួយក្រុមទៀត ស្លាប់ពីនរកចូលទៅកាន់នរកដោយអាការៈយ៉ាងនេះ កប្បក៏កន្លងផុតទៅអស់ ៩២កប្ប។

បន្ទាប់មក ក្នុងភទ្ទកប្បនេះ កាលព្រះពុទ្ធព្រះនាមថា កស្សបៈ ជនអ្នកមានចិត្តឥស្សា និងមច្ឆរិយៈគ្របសង្កត់ទាំងនោះ ក៏កើតជាប្រេត ។ កាលនោះមនុស្សទាំងឡាយថ្វាយទាន ឧទ្ទិសដើម្បីប្រយោជន៍ដល់ពួកប្រេតដែលជាញាតិរបស់ខ្លួនថា សូមទាននេះចូរមានដល់ពួកញាតិរបស់យើង ។ ប្រេតទាំងនោះក៏បាននូវសម្បត្តិ ។ ខណៈនោះប្រេតពួកនេះ ឃើញដូច្នោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគព្រះនាមកស្សបៈ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើយ៉ាងណាហ្ន៎ ពួកខ្ញុំព្រះអង្គទើបនឹងបានសម្បត្តិយ៉ាងនេះ។ ព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ពួកអ្នកទាំងឡាយនូវមិនបានសម្រេចទេ តែថាក្នុងអនាគត ព្រះពុទ្ធព្រះនាមថា គោតម ក្នុងកាលនៃព្រះដ៏មានព្រះភាគអង្គនោះ នឹងមានព្រះរាជាព្រះនាមថា ពិម្ពិសារ ព្រះរាជាអង្គនោះ ជាញាតិរបស់

អ្នកកាលពី ៩២ កប្បមុន ។ ព្រះរាជានឹងថ្វាយទាន ដល់ព្រះពុទ្ធ ឧទ្ទិសចំណែកកុសលដល់ពួកអ្នកទាំងឡាយ គ្រានោះ ពួកអ្នកទាំងឡាយនឹងបាន ។ បានឮថា កាលព្រះពុទ្ធមានព្រះពុទ្ធដីកាយ៉ាងនេះហើយព្រះពុទ្ធតម្រាស់នោះ បានប្រាកដដល់ប្រេតទាំងនោះហាក់បីដូចត្រាស់ថា ពួកអ្នកទាំងឡាយនឹងបានក្នុងថ្ងៃស្អែកនេះ ។

តមក ពេលកន្លងទៅចន្លោះ ១ ពុទ្ធន្តរ ព្រះមានព្រះភាគរបស់ពួកយើង ក៏ស្ដេចឧប្បត្តិឡើងក្នុងលោក ។ ព្រះរាជឱរសទាំង ៣ ព្រះអង្គនោះ ក៏ចុតិពីទេវលោកព្រមដោយបរិវារចំនួន ២,៥០០ នាក់ ទាំងនោះទៅកើតក្នុងត្រកូលព្រាហ្មណ៍ទាំងឡាយក្នុងដែនមគធៈ បួសជាឥសីដោយលំដាប់ បានជាជដិល ៣ នាក់ក្នុងគយាសីសប្រទេស ។ រាជបុរសអ្នកនាំស្បួយ សារអាករ ក្នុងជនបទបានជាព្រះបាទពិម្ពិសារបុត្រគហបតិ ជាអ្នករក្សាឃ្លាំងបានជាមហាសេដ្ឋីឈ្មោះ វិសាខៈ ភរិយារបស់អ្នករក្សាឃ្លាំងនោះបានជាសេដ្ឋីធីតាឈ្មោះ ធម្មទិន្នា ។ បរិស័ទដែលនៅសល់ កើតជារាជបរិវាររបស់ព្រះបាទពិម្ពិសារទាំងអស់ ។

ព្រះដ៏មានព្រះភាគរបស់យើងស្ដេចឧប្បត្តិឡើងក្នុងលោកកន្លងទៅ ៧ សប្ដាហ៍ក៏ស្ដេចមកកាន់ក្រុងពារាណសី ដោយលំដាប់ប្រកាសព្រះធម្មចក្រ ប្រោសបញ្ចវគ្គិយជាដើម រហូតដល់

ទ្រង់ណែនាំជដិល ៣ នាក់ ដែលមានបរិវារ ២,៩០០នាក់ ទើបស្តេចទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងក្រុងរាជគ្រឹះនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រោសព្រះបាទពិម្ពិសារ ដែលស្តេចចូលទៅគាល់ក្នុងថ្ងៃនោះឯង ឱ្យតាំងនៅក្នុងសោតាបត្តិផល ព្រមដោយព្រាហ្មណ៍និងគហបតិអ្នកមគធៈ ១១ នវុតិ ។ គ្រានោះបានសម្តែងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តព្រះបាទពិម្ពិសារក្នុងថ្ងៃស្អែក ។ លុះដល់ថ្ងៃព្រឹកឡើង ដែលស្តេចសក្កទេវរាជកំពូលលើពពួកទេព្តា ទ្រង់សរសើរដោយគាថាទាំងឡាយជាដើមយ៉ាងនេះថា៖

**ទន្តោ ទន្តេហិ សហ បុរាណជដិលេហិ វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ រាជគហំ ចាវិសិ ភគវា ។**

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ(នូវឥន្ទ្រិយ) មានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះមួយអន្លើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ(នូវឥន្ទ្រិយ)ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ(ចាកអាសវធម៌)”។

ស្តេចយាងឆ្ពោះទៅក្រុងរាជគ្រឹះទ្រង់ទទួលមហាទាន ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ។ ប្រេតទាំងនោះឈរចោមរោមដោយសង្ឃឹមថា ពេលនេះព្រះរាជាចាត់ចែងទ្រង់នឹង

ឧទ្ទិសទានដល់ពួកយើង កាលនេះទ្រង់ចាត់ចែងទានឧទ្ទិសដល់ពួកយើង ។ ចំណែកព្រះបាទពិម្ពិសារថ្វាយទានហើយទ្រង់ព្រះតម្រិះថា ព្រះដ៏មានព្រះភាគនឹងគប្បីទ្រង់គង់ប្រថាប់នៅក្នុងទីណាហ្ន៎ ព្រះតម្រិះចំពោះតែរឿងដែលប្រថាប់នៅរបស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ទើបទ្រង់មិនបានឧទ្ទិសទាននោះដល់នរណាៗ ។

ប្រេតទាំងឡាយអស់សង្ឃឹម នៅពេលពាក់កណ្ដាលយប់ទើបនាំគ្នាធ្វើសំឡេងប្លែកៗគួរឱ្យតក់ស្លុតពន់ពេក ក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ស្លុតព្រះហឫទ័យខ្លាចក្រែង ដល់ពេលព្រឹកឡើង ទើបក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេងដូចនេះ តើអ្វីនឹងមានដល់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រសូមទ្រង់កុំខ្លាចឡើយ មិនមានរឿងអន្តរាយអ្វីៗដល់មហាបពិត្រទេ ក៏ប៉ុន្តែពួកព្រះញាតិចាស់ៗ របស់មហាបពិត្រកើតជាប្រេតរមែងមាន ប្រេតទាំងនោះត្រាច់ទៅអស់ ១ ពុទ្ធន្តរ សង្ឃឹមចំពោះមហាបពិត្រថា ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធ ហើយទ្រង់នឹងឧទ្ទិសចំណែកកុសលដល់ពួកយើង ។ កាលពីថ្ងៃម្សិល មហា-បពិត្រទ្រង់មិនបានឧទ្ទិស ចំណែកកុសលដល់ប្រេតពួកនោះ ប្រេតពួកនោះអស់សង្ឃឹម ទើបនាំគ្នាធ្វើសំឡេងខុសប្លែកដូច្នេះ ។ ព្រះបាទពិម្ពិសារក្រាបទូលថា ខ្ញុំព្រះអង្គកាលនេះ ពេលខ្ញុំព្រះ

អង្គថ្វាយទាន ពួកគេក៏គួរនឹងបានឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្របាន ។

ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ប្រសិនបើដូច្នោះ សូមព្រះដ៏មានព្រះភាគ ទ្រង់ប្រោសទទួលនិមន្តសោយភត្តាហារវេលាព្រឹកនេះរបស់ខ្ញុំព្រះអង្គផង ខ្ញុំព្រះអង្គនឹងចាត់ចែងឧទ្ទិសទានដល់ប្រេតពួកនោះ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ព្រះរាជាស្ដេចចូលទៅកាន់ព្រះរាជនិវេសន៍ចាត់ចែងមហាទាន ហើយឱ្យក្រាបទូលវេលាភត្តាហារដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគស្ដេចយាងទៅកាន់ព្រះរាជនិវេសន៍ ប្រថាប់ខាងលើពុទ្ធាសនៈដែលគេចាត់ចែងទុក ព្រមដោយភិក្ខុសង្ឃ ។ ប្រេតពួកនោះនាំគ្នាទៅឈរនៅក្រៅជញ្ជាំងផ្ទះជាដើមដោយសង្ឃឹមថា ថ្ងៃនេះពួកយើងគង់នឹងបានអ្វីខ្លះ ។ ព្រះដ៏មានព្រះភាគទ្រង់ញុំាងព្រះរាជាឱ្យបានឃើញពពួកប្រេតទាំងអស់ ។ ព្រះរាជាថ្វាយទឹកទក្ខិណោទក ហើយទ្រង់ឧទ្ទិសថា សូមទាននេះចូរមានដល់ពួកញាតិរបស់យើង។ នៅពេលនោះឯង ស្រះបោក្ខរណីដេរដាសទៅដោយឈូក ក៏កើតដល់ប្រេតពួកនោះ ។ ប្រេតពួកនោះ ក៏ងូតទឹក និងផឹកទឹកស្រះបោក្ខរណីនោះរម្ងាប់សេចក្ដីក្រវល់ក្រវាយ សេចក្ដីលំបាកនឹងស្រេកឃ្លានបាន ហើយមានពណ៌សម្បុរដូចមាស ។ លំដាប់

នោះ ព្រះរាជាថ្វាយយាគូ របស់ទំពាស៊ី របស់បរិភោគជាដើម ហើយទ្រង់ឧទ្ទិសក្នុងខណៈ ពេលនោះឯង បាយ យាគូ របស់ទំពាស៊ី និងរបស់បរិភោគដែលជារបស់ទិព្វ ក៏កើតដល់ពួកប្រេតនោះ ។ ប្រេតពួកនោះ ក៏នាំគ្នាបរិភោគរបស់ជាទិព្វទាំងនោះ មានឥន្ទ្រិយស្រស់បស់ ។ លំដាប់នោះ ព្រះរាជាថ្វាយសំពត់ និងសេនាសនៈជាដើម ទ្រង់ឧទ្ទិសចំណែកបុណ្យឱ្យស្រាប់តែពេលនោះ គ្រឿងអលង្ការផ្សេងៗ មានសំពត់ទិព្វ យានទិព្វ ប្រាសាទទិព្វ គ្រឿងកម្រាលនិងទីដេកជាដើមជាទិព្វ ក៏កើតដល់ប្រេតពួកនោះ ។ សូម្បីទ្រព្យសម្បត្តិរបស់ប្រេតពួកនោះ ប្រាកដគ្រប់យ៉ាង ដោយប្រការណាព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ក៏អធិដ្ឋាន (ឱ្យព្រះរាជាទ្រង់ឃើញ)ដោយប្រការនោះ ។ ព្រះរាជាក៏ទ្រង់សប្បាយព្រះរាជហឫទ័យយ៉ាងខ្លាំង ។ បន្ទាប់ពីនោះព្រះដ៏មានព្រះភាគសោយស្រេចហើយទ្រង់ហាមភត្តាហារហើយបានត្រាស់ព្រះគាថាទាំងនេះថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើម ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ មាតិកានេះថា **យេន យត្ថ យទា យស្មា តិរោកុឌ្ឌំ បកាសិតំ បកាសយិត្វា តំ សព្វំ** ក៏ជាចំណែកនៃអត្ថហើយ ទាំងដោយសង្ខេប ទាំងដោយពិស្តារ ។ ឥឡូវនេះ នឹងពោលពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនេះ តាមលំដាប់ទៅ ។

## ពណ៌នាគាថាទី ១

នឹងពណ៌នាសេចក្ដីក្នុងគាថាដំបូងសិន ។ ចំណែកខាងក្រៅនៃជញ្ជាំងទាំងឡាយហៅថា **តិរោកុឌ្ឍ** ។ បទថា **តិដ្ឋន្តិ** ជាបទពោលអំពីឥរិយាបថឈរ ព្រោះហាមឥរិយាបថអង្គុយជាដើម ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់អំពីពួកប្រេតដែលឈរនៅត្រង់ចំណែកដទៃនៃជញ្ជាំងផ្ទះ ទុកក្នុងទីនេះថា **តិរោកុឌ្ឍេសុ តិដ្ឋន្តិ** នាំគ្នាឈរនៅត្រង់ខាងក្រៅជញ្ជាំងផ្ទះ ដូចលោកពោលអំពីឫទ្ធិផ្សេងៗ ដែលទៅក្នុងចំណែកដទៃនៃកំពែងនិងចំណែកដទៃនៃភ្នំថា ទៅក្រៅកំពែងក្រៅភ្នំមិនរាំងស្ទះដូច្នេះ ។ ក្នុងបទថា **សន្ធិសឹឃាដកេសុ ច** នោះ ផ្លូវបែកជា ៤ ឬសូម្បីត្រង់ទីតនៃផ្ទះទីតនៃជញ្ជាំង និងស៊ុមបង្អួច លោកហៅថា **សន្ធិ** ។ ផ្លូវបែកជា ៣ លោកហៅថា សឹឃាដកៈ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើពាក្យនោះទុកក្នុងកន្លែងតែមួយ ភ្ជាប់ជាមួយនឹងពាក្យដើម ទើបត្រាស់ថា សន្ធិ**សិង្ឃាដកេសុ ច** ។ បទថា **ទ្វារពាហាសុ តិដ្ឋន្តិ** បានដល់ ឈរផ្អែកមាត់ទ្វារនគរ និងទ្វារផ្ទះ ។ ផ្ទះញាតិអំពីមុនក្ដី ផ្ទះរបស់ខ្លួនដែលធ្លាប់គ្រប់គ្រងជាម្ចាស់របស់ក្ដី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុងពាក្យថា **អាគន្ត្វា សកំ ឃរំ នេះ ។** ព្រោះហេតុដែលប្រេតពួកនោះ នាំគ្នាមកដោយត្រឹមតែសញ្ញាយល់ថា ជាផ្ទះរបស់ខ្លួន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ដល់ផ្ទះពីរនោះថា **អាគន្ត្វា សកំ ឃរំ** មកកាន់ផ្ទះរបស់ខ្លួន ។

## ពណ៌នាគាថាទី ២

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងចំពោះព្រះរាជាអំពីប្រេតជាច្រើន ដែលនាំគ្នាមកកាន់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ដែលជាញាតិអំពីមុនក៏ដោយ សូម្បីខ្លួនមិនធ្លាប់គ្រប់គ្រងមកអំពីមុន ដោយសម្គាល់ថា ជាផ្ទះរបស់ខ្លួន នាំគ្នាឈរនៅខាងក្រៅជញ្ជាំងត្រង់ផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ និងមាត់ទ្វារ សោយផលនៃសេចក្ដីប្រណែនឫស្យា និងសេចក្ដីកំណាញ់ ពួកខ្លះមានពុកមាត់ និងសក់វែង មុខខ្មៅ មានអវយវៈតូចធំចង់សំយុង និងយារ ស្គមកំព្រឹងមានពណ៌ខ្មៅដូចដើមត្នោតត្រូវភ្លើងឆេះ ឈរនៅក្នុងទីនោះៗ ពួកខ្លះមានរាងកាយត្រូវអណ្ដាតភ្លើងដែលតាំងឡើងពីក្នុងពោះ លៀនចេញតាមមាត់ព្រោះការកកិតគ្នានៃឈើកកិតភ្លើង គឺការស្រេកឃ្លានឆេះរោលរាល ពួកខ្លះមិនអាចបរិភោគបានតាមត្រូវការ ព្រោះមានបំពង់-កមានទំហំតូចប៉ុនរន្ធគូថម្ជុល និងព្រោះមានពោះធំដូចភ្នំ ពួកខ្លះមានរាងកាយមិនគួរឱ្យចង់មើលប្លែកៗ និងគួរឱ្យព្រឺខ្លាចណាស់ មានឈាមខ្ទុះ ទឹករំអិលជាដើមដែលហូរចេញពីដំបៅបូសដែលបែករបស់គ្នានិងគ្នា ឬរបស់សត្វពួកដទៃក្រេបជញ្ជាក់ដូចទឹកអម្រឹក ទើបត្រាស់ថា៖

**តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច**

**ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វា សកំ ឃរំ ។**

ប្រេតទាំងឡាយមកកាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុងនិងទ្វារផ្ទះ ទាំងឡាយខ្លះ ។

កាលទ្រង់សម្ដែងសេចក្ដីនៃកម្ម ដែលប្រេតទាំងអស់នោះធ្វើមកហើយជាកម្មទារុណ ទើបត្រាស់គាថាទី ២ ថា **បហុតេ អន្នបានម្ហិ** ជាដើម ។ បណ្ដាបទាំងនោះ បទថា **បហុតេ** បានដល់មិនតិច ។ លោកអធិប្បាយថា ច្រើនទាល់តែល្មមត្រូវការ ។ យក **ភ** ជា **ហ** ដូចក្នុងប្រយោគជាដើមថា **បហុ សន្តោ ន ភរតិ** បុគ្គលជាអ្នកស្ដុកស្ដម្ភ តែមិនចិញ្ចឹម(មាតាក្ដី បិតាក្ដី) ។ តែអាចារ្យពួកខ្លះសូត្រថា **បហូតេ** ក៏មាន **ពហូកេ** ក៏មាន ។ បាលីទាំងពីរនេះមិនត្រឹមត្រូវទេ ។ បាយផង ទឹកផង ឈ្មោះថា បាយនិងទឹក ។ របស់ទំពាស៊ីផង របស់បរិភោគផងឈ្មោះថា របស់ទំពាស៊ី និងរបស់បរិភោគ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងអាហារ ៤ យ៉ាង គឺរបស់បរិភោគ របស់ផឹក របស់ទំពាស៊ី របស់ភ្លក្ស ដោយបទនេះ ។ បទថា **ឧបដ្ឋិតេ** បានដល់ ចូលទៅតាំងទុក ។ លោកអធិប្បាយថា រៀបចំតុបតែងរួបរួម ។ បទទាំងឡាយថា **ន តេសំ កោចិ សរតិ សត្តានំ** សេចក្ដីថា កាលសត្វទាំងអស់នោះកើតក្នុងបេត្តិវិស័យ គឺនរណាមួយមិនថាជាមាតាបិតា ឬបុត្រក៏

មិនរឭកដល់ ។ ព្រោះហេតុអ្វី ព្រោះកម្មជាបច្ច័យគឺសេចក្ដីកំណាញ់ដែលខ្លួនធ្វើ ព្រមទាំងដោយការបដិសេធការទទួលនិងការឱ្យជាដើមជាបច្ច័យ ។ ព្រោះថា កម្មរបស់សត្វពួកនោះមិនឱ្យញាតិនឹកដល់ ។

## ពណ៌នាគាថាទី ៣

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងថា មិនមានញាតិណាៗ ដែលគួរនឹងរលឹកដល់ព្រោះកម្មដែលមានវិបាកជាទុក្ខក្ដៅក្រហាយ ដែលសត្វទាំងអស់នោះ ធ្វើទុកជាបច្ច័យដល់សត្វដែលប្រេតទាំងឡាយនោះ ដែលត្រាច់ទៅបំណងចំពោះញាតិទាំងឡាយថា កាលបាយទឹកជាដើមដ៏ច្រើន ដែលញាតិចូលទៅតាំងទុក(ក្នុងសង្ឃ) ញាតិទាំងឡាយ នឹងគប្បីឱ្យអ្វីៗឧទ្ទិសដល់ពួកយើងខ្លះយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់ថា

**បហុតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ**
**ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា ។**

កាលបើបាយទឹក បង្អែម និងចម្អាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយ នឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។

កាលទ្រង់សរសើរទាន ដែលព្រះរាជាថ្វាយ ឧទ្ទិសដល់ពួកព្រះញាតិ សាលោហិតរបស់ព្រះរាជា ដែលកើតក្នុងបេត្តិវិស័យ(កើតជាប្រេត)ទៀត ទើបត្រាស់ព្រះគាថាទី ៣ ថា **ឯវំ ទទន្តិ**

**ញាតីនំ** ជាដើម ។

បណ្ដាបទនោះ សព្ទថា **ឯវំ** ជាពាក្យឧបមា ។ ពាក្យថា **ឯវំ** នោះ សម្ព័ន្ធសេចក្ដីជា ២ ន័យគឺ ១ ជនទាំងឡាយណាដែលអាណិត ជនទាំងឡាយនោះ រមែងឱ្យបាយទឹកជាដើម ដើម្បីញាតិទាំងឡាយ កាលញាតិណាៗ សូម្បីរឰកមិនឃើញ ព្រោះកម្មរបស់សត្វពួកនោះ ជាបច្ច័យយ៉ាងនេះ ។ ២ ថ្វាយព្រះពរមហារាជ ជនទាំងឡាយណា ជាអ្នកអាណិត ជនទាំងឡាយនោះ រមែងឱ្យបាយទឹកដ៏ស្អាត ប្រណីត ជាកប្បិយៈរបស់គួរតាមកាលដើម្បីញាតិទាំងឡាយ ដូចជាមហាបពិត្រ ថ្វាយទានដូច្នោះ ។

បទថា **ទទន្តិ** បានដល់ ឱ្យឧទ្ទិស ប្រគល់ឱ្យ ។ បទថា **ញាតីនំ** បានដល់អ្នកដែលទាក់ទិនខាងមាតា និងខាងបិតា ។ បទថា **យេ** បានដល់ ពួកណាមួយមិនថា បុត្រធីតា ឬបងប្អូន ។ បទថា **ហោន្តិ** ប្រែថា រមែងមាន ។ បទថា **អនុកម្បកា** បានដល់ដែលប្រាថ្នាប្រយោជន៍ ដែលស្វែងរកប្រយោជន៍អនុគ្រោះ ។ បទថា **សុចឹ** បានដល់ គ្មានមន្ទិល គួរសរសើរ ស្រស់ថ្លាប្រកបដោយធម៌ បានមកដោយធម៌ ។ បទថា **បណីតំ** បានដល់ ខ្ពស់បំផុត ប្រសើរបំផុត ។ បទថា **កាលេន** បានដល់ តាមកាលដែលពួកប្រេតដែលជាញាតិមកឈរនៅខាងក្រៅជញ្ជាំងផ្ទះជាដើម ។

បទថា **កប្បិយំ** បានដល់ គួរសមរម្យសមគួរដល់ការបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា **បានភោជនំ** បានដល់ ទឹក និងបាយ ។ ក្នុងទីនេះ លោកបំណងយកទេយ្យវត្ថុគ្រប់យ៉ាងដោយលើកយកបាយ និងទឹកជាប្រធាន ។

**ពណ៌នាគាថាទី ៤ សម្ព័ន្ធជាមួយគាថាទី ៣**

ព្រះដ៏មានព្រះភាគដែលទ្រង់សរសើរបាយ និងទឹកដែលព្រះបាទមគធរដ្ឋទ្រង់ថ្វាយដើម្បីអនុគ្រោះក្រុមញាតិសាលោហិតដែលជាប្រេតយ៉ាងនេះ ទើបត្រាស់ថា៖

**ឯវំ ទេន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា**
**សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ។**

ញាតិទាំងឡាយណាជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ។

កាលព្រះមានព្រះភាគទ្រង់សម្ដែងឧបការៈនៃទាន ដែលឱ្យហើយ ជាការឱ្យដើម្បីញាតិពួកនោះទៀត ទើបត្រាស់ពាក់កណ្ដាលដើមនៃគាថាទី៤ថា **ឥទំ វោ ញាតីនំ ហោតុ** ជាដើម ។ គប្បីសម្ព័ន្ធសេចក្ដីជាមួយនឹងពាក់កណ្ដាលដើមនៃគាថាទី៣ ថា

**ឯវំ ទេន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា**
**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះញាតិទាំងឡាយនោះ រមែងឱ្យនូវបាយ និងទឹកយ៉ាងនេះថា ទាននេះចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបានដល់នូវសេចក្ដីសុខ ។ ព្រោះហេតុនោះ ដូចអាការៈដែលគប្បីឱ្យដែលទ្រង់ធ្វើហើយដោយ **ឯវំ** ស័ព្ទ ដែលមានអត្ថថា អាការៈក្នុងពាក្យនេះថា ជនទាំងឡាយនោះ រមែងឱ្យដោយអាការៈយ៉ាងនេះថា សូមទាននេះឯងចូរមានដល់ញាតិទាំងឡាយ មិនមែនដោយអាការៈយ៉ាងដទៃ ។

បណ្ដាបទទាំងនោះ បទថា **ឥទំ** ជាបទសម្ដែងដូចទេយ្យធម៌ ។

បទថា **វោ** គ្រាន់តែជានិបាតតែម្យ៉ាង មិនមែនឆដ្ឋីវិភត្តដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា** ។ ឬថា **យេហិ វោ អរិយា** ។ បទថា **ញាតីនំ ហោតុ** សេចក្ដីថា ចូរមានដល់ញាតិទាំងឡាយ ដែលកើតក្នុងបេត្តិវិស័យ ។ បទថា **សុខិតា ហោន្តុ ញាតយោ** សេចក្ដីថា សូមពួកញាតិដែលចូលដល់បិត្តិវិស័យនោះ ចូរជាអ្នកសោយនូវផលទាននេះ ចូរមានសេចក្ដីសុខចុះ ។

## ពណ៌នាវគ្គខាងចុងនៃគាថាទី ៤

សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី ៥ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងឧបការៈនៃទាន ដែលបុគ្គលគប្បី

ឱ្យដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យ ទើបត្រាស់ថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខចុះ ព្រោះហេតុដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ កម្មដែលបុគ្គលម្នាក់ធ្វើហើយរមែងមិនឱ្យផលដល់បុគ្គលម្នាក់ទៀត ប៉ុន្តែវត្ថុនោះដែលញាតិឧទ្ទិសឱ្យយ៉ាងនោះតែម្យ៉ាង រមែងជាបច្ច័យដល់កុសលកម្មរបស់ញាតិទាំងឡាយ ។ ព្រោះហេតុនោះ កាលទ្រង់សម្តែងឧបការៈនៃកុសលកម្មដែលឱ្យកើតផលភ្លាមៗ ព្រោះវត្ថុនោះនុ៎ះឯងទៀត ទើបត្រាស់ពាក់កណ្តាលក្រោយនៃគាថាទី ៤ ថា៖

**តេ ច តត្ថ** និងពាក់កណ្តាលដើមនៃគាថាទី ៥ ថា **បហុតេ អន្នបានម្ហិ ។**

ពាក់កណ្តាលខាងដើម និងពាក់កណ្តាលខាងចុងនៃគាថានោះ មានសេចក្តីអធិប្បាយទុកថា ប្រេតដែលជាញាតិទាំងអស់នោះមកជុំវិញ មករួមគ្នា ប្រជុំនៅក្នុងកន្លែងជាមួយគ្នា ក្នុងទីដែលញាតិឱ្យទាននោះ ។ លោកអធិប្បាយទុកថា ប្រេតទាំងអស់នោះមកដោយប្រពៃ មករួមគ្នា មកព្រមគ្នា ដើម្បីសេចក្តីត្រូវការយ៉ាងនេះថា ញាតិទាំងឡាយរបស់យើងនឹងឧទ្ទិសទាននេះដើម្បីប្រយោជន៍ដល់យើងទាំងឡាយ ។ បទថា **បហុតេ អន្នបានម្ហិ**

សេចក្តីថា ក្នុងបាយទឹកដែលញាតិឧទ្ទិសឱ្យដើម្បីខ្លួនមានច្រើន នោះ ។ បទថា **សក្កច្ចំ អនុមោទរេ** សេចក្តីថា ប្រេតទាំងឡាយ នោះជឿជាក់ផលកម្ម មិនលះសេចក្តីគោរពកោតក្រែង មានចិត្ត មិនកន្ទក់កន្ទេញ រមែងត្រេកអរអនុមោទនា កើតបីតិរីករាយថា ទាននេះ ចូរមានផលដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ យើងទាំងឡាយ ។

## ពណ៌នាវគ្គខាងចុងនៃគាថាទី ៥

សម្ព័ន្ធជាមួយវគ្គខាងដើមនៃគាថាទី៦ព្រះដ៏មានព្រះភាគ ជាម្ចាស់ កាលទ្រង់សម្តែងឧបការៈនៃកុសលកម្មឱ្យផលភ្លាមៗ ដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យយ៉ាងនេះ ទើប ត្រាស់ថា៖

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា
បហុតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ ។

ចំណែកប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មក ជួបជុំគ្នា ហើយក្នុងមន្ទីរឱ្យទាននោះ កាលបើបាយ និងទឹក មាន ល្មមគ្រាន់ ក៏អនុមោទនាដោយគោរព។កាលទ្រង់សម្តែងអាការៈ សរសើរ ប្រាកដដល់ញាតិទាំងឡាយ របស់ប្រេតទាំងអស់នោះ ដែលសោយផលនៃកុសលកម្ម ដែលកើតព្រោះអាស្រ័យពួក ញាតិទៀត ទើបត្រាស់ពាក់កណ្តាល ក្រោយនៃគាថាទី ៥ ថា **ចិរំ**

**ជីវន្តុ** និងពាក់កណ្តាលដើមនៃគាថាទី ៦ ថា **អម្ហាកញ្ច កតា បូជា ។** ពាក់កណ្តាលខាងក្រោយ និងពាក់កណ្តាលខាងដើមនៃគាថាទាំងអស់នោះ មានសេចក្តីថា បទថា **ចិរំ ជីវន្តុ** បានដល់មានជីវិតរស់នៅយឺនយូរមានអាយុវែង ។ បទថា **នោ ញាតី** ប្រែថា ញាតិទាំងឡាយរបស់ពួកយើង ។ បទថា **យេសំ ហេតុ** បានដល់ ព្រោះអាស្រ័យញាតិពួកណា ព្រោះហេតុនៃញាតិពួកណា ។ បទថា **លភាមសេ** ប្រែថា បាន ។ ពួកប្រេតពោលនូវសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។ មែនពិត ទក្ខិណារមែងសម្រេចផលគឺ ឱ្យកើតផលក្នុងខណៈនោះបានដោយអង្គ ៣ គឺះ

**១-បេតានំ អត្តនោ អនុមោទនេន** = ដោយការអនុមោទនាដោយខ្លួនឯង របស់ប្រេតទាំងឡាយ ។

**២-ទាយកានំ ឧទ្ទេសេន** = ដោយការឧទ្ទិសរបស់ទាយកទាំងឡាយ ។

**៣-ទក្ខិណេយ្យ សម្បទាយ**= ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ។

បណ្តាអង្គ ៣ នោះ ទាយកទាំងឡាយជាអង្គពិសេស ព្រោះហេតុ នោះប្រេតទាំងឡាយទើបពោលថា **យេសំ ហេតុ លភាមសេ** រមែងបានព្រោះហេតុនៃញាតិ(ដែលជាទាយក) ពួកនោះ ។ បទថា **អម្ហាកញ្ច កតា បូជា** សេចក្តីថា ញាតិទាំងឡាយ

ដែលឧទ្ទិសទាននេះយ៉ាងនេះថា សូមទាននេះចូរមានដល់ញាតិរបស់យើងដូច្នេះ ឈ្មោះថា ធ្វើការបូជាដល់ពួកយើងហើយ ។ បទថា **ទាយកា ច អនិប្ផលា** សេចក្តីថា កម្មដែលសម្រេចមកអំពីការបរិច្ចាគ ដែលទាយកធ្វើហើយក្នុងសន្តានណា ទាយកទាំងឡាយឈ្មោះថា មិនឥតផល ក៏ព្រោះកម្មនោះឱ្យផល ក្នុងសន្តាននោះប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះអ្នកជំទាស់ពោលថា ញាតិទាំងឡាយ ដែលចូលដល់បេត្តិវិស័យបានប៉ុណ្ណោះឬ ឬថាសូម្បីអ្នកដទៃៗ ក៏បាន ។

សូមពន្យល់ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រូវព្រាហ្មណ៍ឈ្មោះថា ជាណុស្សោណិ ទូលសួរហើយ ក៏ទ្រង់ព្យាករណ៍សេចក្តីនេះទុកដូច្នេះថា ក្នុងសេចក្តីនេះ តថាគតនឹងគប្បីពោលពាក្យអ្វី ។ សមដូចដែលព្រះសង្គីតិកាចារ្យពោលទុកដូច្នេះថា ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា៖

បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឱ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធាហើយឧទ្ទិសថា ទាននេះសូមឱ្យសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសាលោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរទេ ប្រេតទាំងឡាយ

ជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះបានដែរឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរតើដូចម្តេច ទីដែលមិនគួរតើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ឃើញខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណាជាអាហារសម្រាប់សត្វទាំងឡាយ កើតក្នុងនរកសត្វនរកនោះ តែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងនរកនោះដោយសារអាហារនោះ សត្វនរកនោះ ស្ថិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផលដល់សត្វ ដែលស្ថិតនៅក្នុងទីណា ទីនោះឯង ហៅថាទីមិនគួរ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយ ស្លាប់ទៅក៏ទៅកើតក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះដោយអាហារនោះ សត្វតិរច្ឆាននោះ ស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯ

បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត។ល។ មានសេចក្តីយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណាជាអាហារសម្រាប់ពួកមនុស្ស ។ល។ ក៏ទៅកើតក្នុងពួកទេវតា អាហារណាជាអាហារសម្រាប់ពួកទេវតា ទេវតានោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតក្នុងបេត្តិវិស័យ អាហារណាជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងបេត្តិវិស័យ ប្រេតនោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្រអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឱ្យនូវទានណាដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផលដល់សត្វ ដែលស្ថិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីគួរ ។

ជាណុស្សោណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះ

គោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិ សាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណា បរិភោគទាននោះ ។ អើព្រាហ្មណ៍ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាន ។

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណាបរិភោគទាននោះ ។ នែព្រាហ្មណ៍ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឱ្យទាន មិនមែនជាគ្មានផលទេ ។

## ពណ៌នាវគ្គខាងចុងនៃគាថាទី ៦

សម្ព័ន្ធជាមួយគាថាទី៧ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សរសើរព្រះរាជា ព្រោះទ្រង់អាស្រ័យសម្បត្តិរបស់ក្រុមព្រះញាតិវង្សានុវង្ស ក្នុងជាតិមុនរបស់ព្រះបាទមគធរដ្ឋ ដែលចូលដល់បេត្តិវិស័យ ទើបទ្រង់សម្ដែងថា ថ្វាយព្រះពរមហាបពិត្រព្រះញាតិវង្សានុវង្សរបស់មហាបពិត្រទាំងអស់នេះ ត្រេកអរនាំ

គ្នាសរសើរក្នុងទានសម្បទានេះ ទើបព្រះមានព្រះភាគត្រាស់ថា

**ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ**

**អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា ។**

យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយក្តី ញាតិទាំងឡាយជាអ្នកឱ្យទានក្តី មិនមែនជាឥតផលឡើយ ។ កាលទ្រង់សម្តែងការមិនមានហេតុដែលឱ្យបានសម្បត្តិយ៉ាងដទៃ មានកសិកម្ម និងគោរក្ខកម្មជាដើម របស់ពួកប្រេតដែលចូលដល់បេត្តិវិស័យនោះ និងការដែលពួកប្រេតនោះញុំាងជីវិតឱ្យប្រព្រឹត្តទៅដោយទាន ដែលញាតិឱ្យអំពីមនុស្សលោកនេះ ទើបត្រាស់ពាក់កណ្តាលក្រោយនៃគាថាទី ៦ ថា **ន ហិ តត្ថ កសិ អត្ថិ** និងគាថាទី ៧ នេះថា **វណិជ្ជា តាទិសី** ជាដើម ។ ក្នុងគាថានោះ ពណ៌នាសេចក្តីដូច្នេះ ថ្វាយព្រះពរមហាបពិត្រ ក៏ក្នុងបេត្តិវិស័យនោះ មិនមានកសិកម្មដែលពួកប្រេតទាំងអស់នោះនឹងអាស្រ័យ ហើយបានសម្បត្តិ ។ បទថា **គោរក្ខេត្ថ ន វិជ្ជតិ** សេចក្តីថា មិនមែន មិនមានកសិកម្មតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីក្នុងបេត្តិវិស័យនោះ ក៏មិនមានគោរក្ខកម្មដែរ ដែលពួកប្រេតទាំងអស់នោះនឹងអាស្រ័យហើយបានសម្បត្តិ ។ បទថា **វណិជ្ជា**

**តាទិសី នត្ថិ** សេចក្តីថា មិនមានសូម្បីការលក់ដូរ ដែលនឹងជាហេតុឱ្យបានសម្បត្តិរបស់ពួកប្រេតទាំងអស់នោះ ។ បទថា **ហិរញ្ញេន កយាកយំ** សេចក្តីថា ក្នុងបេត្តិវិស័យនោះ មិនមានសូម្បីតែការលក់ទិញដូរ ដោយប្រាក់ដែលជាហេតុបានសម្បត្តិរបស់ប្រេតទាំងអស់នោះ ។ បទថា **ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ** សេចក្តីថា ពួកប្រេតរមែងញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅ ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយទានដែលពួកញាតិ ឬពួកមិត្តសំឡាញ់ឱ្យទៅអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា **បេតា** បានដល់ ពួកសត្វដែលចូលដល់បិត្តិវិស័យ ។ បទថា **កាលគតា** បានដល់ ទៅតាមវេលាស្លាប់របស់ខ្លួន ។ ឬបាលីថា **កាលកតា** មានសេចក្តីអធិប្បាយថា ធ្វើកាលៈ គឺមរណកាល ។ បទថា **តហឹ** បានដល់ ក្នុងបេត្តិវិស័យនោះ ។

## ពណ៌នាពីរគាថាគឺគាថាទី ៨ និងគាថាទី ៩

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់ថា អ្នកដែលធ្វើកាលកិរិយាលះលោកទៅហើយ រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបេត្តិវិស័យនោះ ដោយទានដែលពួកញាតិមិត្តសំឡាញ់ឱ្យហើយអំពីមនុស្សនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីនោះ ដោយសេចក្តីឧបមាទាំងឡាយ ទើបត្រាស់ ២ គាថានេះថា **ឧន្នតេ ឧទកំ វុដ្ឋំ** ជាដើម ។

គាថានោះ មានសេចក្តីថា ទឹកដែលដុំពពុះឱ្យធ្លាក់ចុះលើទីទួល លើគោក លើភូមិភាគដែលខ្ពស់ រមែងហូរចុះទីទំនាប គឺហូរទៅដល់ភូមិភាគ យ៉ាងណា ទានដែលពួកញាតិមិត្តឱ្យអំពីមនុស្សលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយនោះ អធិប្បាយថា បង្កើតផល ប្រាកដផលដល់ក្រុមប្រេតយ៉ាងនោះដូចគ្នា ។

មែនពិត **បេតលោក** ឈ្មោះថា ឋានៈ ទីតាំងនៃសេចក្តីសម្រេចផលនៃទាន ដូចទីទំនាបជាឋានៈដែលទប់ទឹកដែលហូរមក ។ ដូចដែលទ្រង់ត្រាស់ទុកថា **ឥទម្បិ ខោ ព្រាហ្មណា ឋានំ យត្ថ ឋិតស្ស តំ ទានំ ឧបកប្បតិ** ម្នាលព្រាហ្មណ៍ ទាននេះសម្រេចផលដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងជាឈ្មោះថា ទីគួរ ដូច្នេះ ។ ដូចទឹកដែលហូរចុះមកអំពីទួលមានជ្រោះ ចន្លោះភ្នំ ប្រឡាយ ព្រៃក បឹង ជាទន្លេធំពេញចហូរចូល ក៏ធ្វើឲ្យសាគរ គឺសមុទ្រឲ្យពេញប្រៀប យ៉ាងណា ទាន ដែលញាតិមិត្តឲ្យទៅហើយអំពីលោកនេះ រមែងសម្រេចផលដល់ក្រុមប្រេត តាមន័យដែលពោលមកមុនហើយ ដូច្នោះ ។

## ពណ៌នាគាថាទី ១០

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ប្រកាសសេចក្តីនេះថា អ្នកដែលធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបេត្តិវិស័យនោះ ដោយទានដែលញាតិ

មិត្តឱ្យអំពីលោកនេះ ដោយសេចក្ដីឧបមាដូច្នេះហើយ កាល ទ្រង់សម្ដែងទៀតថា ព្រោះហេតុដែលប្រេតពួកនោះ សង្ឃឹម យ៉ាងខ្លាំងថា ពួកយើងនឹងបានអ្វីៗអំពីលោកនេះ ក៏នាំគ្នាមក កាន់ផ្ទះនៃញាតិហើយ ក៏មិនអាចនឹងស្រែកសូមថា សូមលោក ទាំងឡាយ មេត្តាឱ្យរបស់ឈ្មោះនេះ ដល់ពួកយើងចុះ ព្រោះ ហេតុនោះ កុលបុត្រកាលរឭកដល់រឿងដែលគួររលឹកទាំងអស់ នេះ គប្បីឱ្យទក្ខិណាដើម្បីពួកប្រេតទាំងអស់នោះ ទើបត្រាស់ គាថានេះថា **អទាសិ មេ** ជាដើម ។

គាថានោះមានសេចក្ដីថា កុលបុត្រកាលរឭកឃើញយ៉ាង នេះថា លោកបានឱ្យទ្រព្យ ឬធញ្ញាហារឈ្មោះនេះដល់យើង លោកបានប្រឹងប្រែងដោយខ្លួនឯង បានធ្វើកិច្ចឈ្មោះនេះដល់ យើង អ្នកនោះជាញាតិ ព្រោះជាប់ទាក់ទងខាងមាតា ឬខាង បិតារបស់យើង អ្នកនោះជាមិត្ត ព្រោះអាចជួយសង្គ្រោះ ដោយ សេចក្ដីស្រឡាញ់ និងអ្នកនោះជាមិត្ត លេងដីជាមួយយើង ដូច្នេះ គប្បីឱ្យទក្ខិណា គឺគប្បីឱ្យទក្ខិណាទានឱ្យដល់ប្រេត ដែលលះ លោកទៅហើយ ។ មានបាលីដទៃទៀតថា **បេតានំ ទក្ខិណា ទជ្ជា ។** បាលីនោះ មានសេចក្ដីថា ឈ្មោះថា **ទជ្ជា** ព្រោះជារបស់ ដែលគប្បីឱ្យ ។ របស់ដែលគប្បីឱ្យនោះគឺជាអ្វី ក៏គឺទក្ខិណាដើម្បី អ្នកដែលលះលោកទៅហើយ ។ ព្រោះហេតុនោះ កុលបុត្រ កាលរឭកដល់លោក អធិប្បាយថា កាលនឹកដល់កិច្ច ដែល

លោកធ្វើមកពីមុនដោយន័យថា លោកបានឱ្យវត្ថុនេះ ដល់យើង ដូច្នេះជាដើម ។ ពាក្យនេះគប្បីជ្រាបថា ជាបឋមាវិភត្ត ចុះក្នុងអត្ថបំណង ជាតតិយាវិភត្ត ។

## ពណ៌នាគាថាទី ១១

ព្រះដ៏មានព្រះភាគជាម្ចាស់កាលទ្រង់សម្តែងអនុស្សរណវត្ថុដែលជាហេតុក្នុងការឱ្យនូវទក្ខិណា ដើម្បីក្រុមប្រេតទាំងឡាយយ៉ាងនេះ ទើបត្រាស់ថាៈ

**អទាសិ មេ អកាសិ មេ ញាតិ មិត្តា សខា ច មេ**

**បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។**

បុគ្គលកាលរកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្រជាសំឡាញ់របស់អញ ដូច្នេះហើយគួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ ។

កាលទ្រង់សម្តែងទៀតថា ជនទាំងឡាយណា មានការយំស្រែក និងសោកសៅជាដើមជាខាងមុខ ព្រោះសេចក្តីស្លាប់របស់ញាតិ ដែលរស់នៅដែលលះលោកទៅហើយ រមែងមិនឱ្យអ្វីៗ គប្បីប្រយោជន៍ដល់ជនអស់នោះ ការយំ និងការសោកសៅជាដើមនោះ របស់ជនទាំងអស់នោះ មានតែធ្វើខ្លួនឱ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ រមែងមិនញ៉ាំងប្រយោជន៍អ្វីៗ ឱ្យសម្រេចដល់

អ្នកដែលលះលោកទៅហើយទេ ទើបត្រាស់គាថានេះថា **ន ហិ រុណ្ណំ វា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **រុណ្ណំ** បានដល់ ការយំ ការទួញសោក ការដែលទឹកភ្នែកស្រក់ ទ្រង់សម្តែងសេចក្តីលំបាកកាយដោយបទនេះ ។ បទថា **សោកោ** បានដល់ សេចក្តីព្រួយសេចក្តីសោកសៅ ។ ទ្រង់សម្តែងសេចក្តីលំបាកចិត្តដោយបទនេះ ។ បទថា **យាវញ្ញា** បានដល់ ការយំសោកសៅណានីមួយ ។ បទថា **បរិទេវនា** បានដល់ ការពណ៌នារៀបរាប់អំពីគុណដោយន័យថា ឱ! កូនតែម្នាក់គត់ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៅកន្ទែងដូច្នេះជាដើម របស់អ្នកដែលត្រូវសេចក្តីវិនាសចាកញាតិគ្រប់សង្កត់ហើយ ។ ទ្រង់សម្តែងសេចក្តីលំបាកវាចា ដោយបទនេះ ។

## ពណ៌នាគាថាទី ១២

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការយំជាដើម មិនជាប្រយោជន៍ថា ការយំរៀបរាប់យ៉ាងនេះយ៉ាងនោះសូម្បីទាំងអស់មិនមានដើម្បីប្រយោជន៍ដល់អ្នក ដែលលះលោកទៅហើយ ការពិតមានតែធ្វើខ្លួនឱ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះញាតិទាំងឡាយក៏ប្រហែលជារស់នៅយ៉ាងនោះដូច្នេះ កាលទ្រង់សម្តែងភាពនៃទក្ខិណាដែលព្រះបាទ មគធរដ្ឋ ទ្រង់ថ្វាយហើយមានប្រយោជន៍ ទើបត្រាស់គាថានេះថា **អយញ្ច ខោ ទក្ខិណា** ដូច្នេះជាដើម ។

គាថានោះ មានសេចក្តីថា ថ្វាយព្រះពរមហារាជ ទក្ខិណានេះឯង មហាបពិត្រ ថ្វាយឧទ្ទិសដល់ក្រុមព្រះញាតិវង្សានុវង្សរបស់មហាបពិត្រ ក្នុងថ្ងៃនេះ ព្រោះហេតុនៃព្រះសង្ឃជាស្រែបុណ្យដ៏កំពូលនៃលោក ព្រោះហេតុនោះ ទក្ខិណានោះគប្បីជាទក្ខិណាដែលទ្រង់តម្កល់ទុកល្អហើយក្នុងសង្ឃ ទើបសម្រេចផល លោកអធិប្បាយថា បង្កើតផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់បេតជនអស់កាលយូរ ។ ក៏បទថា **ឧបកប្បតិ** បានដល់ សម្រេចផលដោយឋានៈ គឺបង្កើតផលក្នុងខណៈនោះភ្លាមមិនយូរឡើយ ។ ដូចជាដាក់ស្តែងភ្លាមមួយរំពេចនោះ ក៏ត្រាស់ថា ក៏សេចក្តីនោះដាក់ស្តែងដល់តថាគតដោយឋានៈយ៉ាងណា ទក្ខិណាដែលសម្រេចផលភ្លាមមួយរំពេចនោះ សូម្បីក្នុងទីនេះក៏ត្រាស់ថា សម្រេចផលដោយឋានៈក៏យ៉ាងនោះ ។ ឋានៈណាទ្រង់ត្រាស់ទុកថា ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលរស់នៅក្នុងបេត្តិវិស័យណា បេត្តិវិស័យនោះឯងជាឋានៈ ដូច្នេះ ។ ទក្ខិណាដែលសម្រេចផលក្នុងឋានៈនោះដែលផ្សេងដោយប្រភេទមាន ខុប្បិបាសិកប្រេត (ប្រេតដែលបៀតបៀនដោយសេចក្តីស្រេកឃ្លាន) វន្តាសប្រេត (ប្រេតដែលស៊ីទឹកមាត់ ស្ទេស្ម កំអួតជាអាហារ) បរទត្តូបជីវិតប្រេត (ប្រេតដែលចិញ្ចឹមជីវិត ដោយអាស្រ័យអាហារដែលអ្នកដទៃឱ្យ) និងនិជ្ឈាមតណ្ហិកប្រេត (ប្រេតដែលត្រូវភ្លើងឆេះរោលឱ្យក្តៅជាប់

ជានិច្ច)ជាដើម ក៏ត្រាស់ថា រមែងសម្រេចផលដោយឋានៈ ដូចជាអ្នកឱ្យកហាបណៈក្នុងលោក គេក៏ហៅថា អ្នកនោះឱ្យកហាបណៈ ដូច្នោះ ។ ប៉ុន្តែនៅក្នុងអត្ថវិកប្បនេះ បទថា **ឧបកប្បតិ** បានដល់ប្រាកដផល លោកអធិប្បាយថា រមែងកើតផល ។

## ពណ៌នាគាថាទី ១៣

*ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងភាពនៃទក្ខិណា ដែលព្រះរាជាថ្វាយហើយមានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា៖*

**អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុបតិដ្ឋិតា**
**ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។**

*លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឱ្យហើយ តម្កល់ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។ ព្រោះហេតុនៃញាតិធម៌ ដែលព្រះរាជាទ្រង់ថ្វាយ ទក្ខិណាទាននេះទ្រង់សម្ដែងហើយ ដោយទ្រង់ធ្វើកិច្ចដែលក្រុមញាតិ គួរធ្វើដល់ក្រុមញាតិ ទ្រង់ធ្វើឱ្យប្រាកដដល់ជនជាច្រើន ឬទ្រង់លើកដូចជាថា ញាតិធម៌ សូម្បីលោកទាំងឡាយ ក៏គប្បីបំពេញដោយការធ្វើកិច្ចដែលក្រុមញាតិគប្បីធ្វើយ៉ាងនោះ ដូចគ្នា មិនគប្បីធ្វើខ្លួនឱ្យក្ដៅក្រហាយដោយការយំជាដើម ដែលឥតប្រយោជន៍ ការបូជាដល់*

ប្រេតដែលព្រះរាជា ទ្រង់ញ៉ាំងក្រុមប្រេតទាំងអស់នោះ ឱ្យប្រសព្វទិព្វសម្បត្តិ ដែលទ្រង់ធ្វើហើយយ៉ាងឱឡារិក និងកម្លាំងរបស់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ ដោយបាយទឹកជាដើម ឈ្មោះថាទ្រង់បំពេញឱ្យហើយ និងបុណ្យមិនមែនតិចទេកាលដែលព្រះរាជាទ្រង់ញ៉ាំងចាគចេតនា មានគុណគឺសេចក្ដីអនុគ្រោះជាដើមជាបរិវារ ឱ្យកើតក៏ទ្រង់ប្រសព្វហើយដូច្នេះ ទើបព្រះមានព្រះភាគទ្រង់ញ៉ាំងព្រះរាជាឱ្យទ្រង់រីករាយដោយគុណ តាមសេចក្ដីពិត ទាំងអស់នេះទៀត ទើបទ្រង់បញ្ចប់ទេសនាដោយព្រះគាថានេះថា៖

**សោ ញាតិ ធម្មោ ច អយំ និទស្សិតោ**
**បេតានបូជា ច កតា ឧឡារា**
**ពលញ្ច ភិក្ខូនមនុប្បទិន្នំ**
**តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ ។**

ញាតិធម៌នោះឈ្មោះថា មហាបពិត្រ បានសម្ដែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ ឈ្មោះថាបានធ្វើហើយផង កម្លាំងកាយនៃភិក្ខុទាំងឡាយឈ្មោះថា បានបំពេញឱ្យហើយផង បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង ។

ន័យមួយទៀត ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ពន្យល់

ព្រះរាជាដោយធម្មិកថាដោយបទគាថានេះថា **សោ ញាតិធម្មោ ច អយំ និទស្សិតោ** ។ មែនពិត ការសម្តែងញាតិធម៌នេះឯង ជាការពន្យល់ញឹកញាប់ក្នុងសេចក្តីនេះ ។ ទ្រង់ប្រកបដោយបទគាថានេះថា **បេតាន បូជា ច កតា ឧឡារា** មែនពិត ការសរសើរថា **ឧឡារា** ក៏ជាការប្រកបដោយការបូជារឿយៗ ក្នុងសេចក្តីនេះ ។

ព្រះមានព្រះភាគទ្រង់ផ្តល់ភាពអង់អាច ដោយបទគាថានេះថា **ពលញ្ច ភិក្ខូនមនុប្បទិន្នំ** ។ មែនពិត ការបំពេញកម្លាំងដល់ភិក្ខុទាំងឡាយ ក៏ជាទាន ម្យ៉ាងក្នុងសេចក្តីនេះ ។ ពាក្យថា **ពលានុប្បទានតា** ជាការដាស់ឱ្យអង់អាច ដោយការបំពេញសេចក្តីឧស្សាហដល់ព្រះរាជានោះ ។ ទ្រង់រីករាយដោយបទគាថានេះថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** ។ មែនពិត ការបញ្ជាក់អំពីការជួបបុណ្យនោះឯង គប្បីជ្រាបថា ជាការឱ្យកើតសេចក្តីរីករាយ ដោយការពណ៌នាគុណតាមសេចក្តីពិត ដល់ព្រះរាជានោះក្នុងសេចក្តីនេះ ។

ក្នុងទីបញ្ចប់នៃទេសនា ការសម្រេចធម៌បានកើតមានដល់សត្វ ៨៤,០០០ ដែលស្តុតចិត្ត ព្រោះការពណ៌នាទោសនៃការចូលដល់បេត្តិវិស័យ ហើយតាំងសេចក្តីព្យាយាមដោយរឹងមាំ ។ សូម្បីដល់ថ្ងៃស្អែកឡើង ព្រះដ៏មានព្រះភាគជាម្ចាស់ ក៏ទ្រង់សម្តែងតិរោកុឌ្ឌសូត្រនេះឯង ដល់ពួកទេវតា និងមនុស្សទាំងឡាយការត្រាស់ដឹងធម៌យ៉ាងនោះ កើតមានដល់ ៧ ថ្ងៃដោយប្រការដូច្នេះ ។

## មាតាសូត្រ

នៅក្នុងព្រះត្រៃបិដកលេខ ៤៧ ទំព័រ ១១៧ ព្រះមានព្រះភាគទ្រង់ត្រាស់រឿង នន្ទមាតាឧទ្ទិសកុសលដល់ស្តេចវេស្សវ័ណ ដែលមានសេចក្តីថាៈ

សម័យមួយ ព្រះមានព្រះភាគ ព្រះសារីបុត្រដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រាច់ទៅកាន់ចារិកក្នុងទក្ខិណាគិរីជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង នន្ទ-មាតាឧបាសិកានៅក្នុងក្រុងឈ្មោះវេឡុកណ្តកៈ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី សូត្របារាយនធម៌ គឺព្រះនិព្វាន ដោយសំឡេងដ៏ពីរោះ ។ សម័យនោះឯង មហារាជឈ្មោះវេស្សវ័ណ ស្តេចចេញទៅអំពីទិសខាងជើង ទៅកាន់ទិសខាងត្បូង ដោយកិច្ចនីមួយ ។ មហារាជឈ្មោះវេស្សវ័ណ បាននន្ទមាតាឧបាសិកាកំពុងសូត្របារាយនធម៌ដោយសំឡេង(ដ៏ពីរោះ) ក៏បង្អង់ឈរចាំស្តាប់ ត្រាតែចប់ពាក្យពោល ។ លុះនន្ទមាតាឧបាសិកាសូត្រនូវបារាយនធម៌ ដោយសំឡេង(ដ៏ពីរោះ)រួចហើយ ក៏នៅស្ងៀម ។ លំដាប់នោះ មហារាជឈ្មោះវេស្សវ័ណ ជ្រាបច្បាស់នូវការចប់នៃកថារបស់នន្ទមាតាឧបាសិកាហើយ ក៏អនុមោទនាថា ម្នាលនាង ពីរោះណាស់ ម្នាលនាង ពីរោះណាស់ ។

(នន្ទមាតាឧបាសិកាសួរថា) បពិត្រព្រះអង្គមានមុខដ៏ចម្រើន ចុះអ្នកជាអ្វី ។

វេ. ម្នាលនាង ខ្ញុំជាមហារាជ ឈ្មោះវេស្សវ័ណ ជាប្អូននៃនាង ។

ន. បពិត្រព្រះអង្គមានមុខដ៏ចម្រើនប្រពៃហើយបើដូច្នោះធម្មបរិយាយដែលខ្ញុំពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។

វេ. វេស្សវ័ណមហារាជពោលថា ម្នាលនាង ប្រពៃហើយពាក្យនុ៎ះសូមជាបណ្ណាការវិសេសដ៏ព្រះអង្គចុះភិក្ខុសង្ឃមានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់បានធ្វើភត្តកិច្ចក្នុងវេលាព្រឹកនឹងមកកាន់វេឡុកណ្ដកនគរ ក្នុងថ្ងៃស្អែកនាងចូលអង្គាសនូវភិក្ខុសង្ឃនោះ ឧទ្ទិសនូវចំណែកបុណ្យដល់ខ្ញុំផង បណ្ណាការយ៉ាងវិសេសនឹងមានដល់ខ្ញុំយ៉ាងនេះឯង ។

គ្រានោះ នន្ទមាតាឧបាសិកា លុះកាលកន្លងទៅ ក៏ប្រើបុរសមួយនាក់ ឱ្យចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្ដម ក្នុងលំនៅរបស់ខ្លួន ។ លំដាប់នោះ ភិក្ខុសង្ឃមានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់ធ្វើភត្តកិច្ចក្នុងពេលព្រឹកនៅឡើយ ក៏សំដៅទៅកាន់វេឡុកណ្ដកនគរ ។ ចំណែកខាងនន្ទមាតាឧបាសិកា ក៏ហៅបុរសមួយនាក់ថា នែបុរសដ៏ចំរើន អ្នកចូរមក អ្នកចូរទៅឯអារាម ចូរក្រាកទូលនូវភត្តកាលចំពោះភិក្ខុសង្ឃថា បពិត្រលោកដ៏ចម្រើនទាំងឡាយ កាលគួរហើយភត្តក្នុង

លំដាប់នៃនន្ទមាតាឧបាសិកាជាម្ចាស់ ក៏សម្រេចហើយ ។ បុរស នោះក៏ទទួលស្តាប់នន្ទមាតាឧបាសិកាថា បាទ អ្នកម្ចាស់ ហើយក៏ សំដៅទៅឯអារាម ក្រាបទូលនូវកាលដល់ភិក្ខុសង្ឃថា បពិត្រ លោកម្ចាស់ទាំងឡាយដ៏ចម្រើន កាលគួរហើយ ភត្តក្នុងលំនៅនៃ នន្ទមាតាឧបាសិកាជាម្ចាស់ ក៏សម្រេចហើយ ។ លំដាប់នោះ ភិក្ខុ សង្ឃមានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាប្រធាន ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅត្រង់លំនៅដែល នន្ទមាតាឧបាសិកានៅ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលស្រេចហើយ ។ ចំណែកខាងនន្ទមាតាឧបាសិកា អង្គាសភិក្ខុសង្ឃ មានព្រះសារីបុត្រនឹងព្រះមោគ្គល្លានជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឧត្តមដោយដៃខ្លួនឯង ឱ្យឆ្អែត ស្កប់ស្កល់ត្រាតែហាមឃាត់ ។ នន្ទមាតាឧបាសិកា លុះកំណត់ដឹងនូវ ព្រះសារីបុត្រដ៏មានអាយុ កាលឆាន់រួច មានព្រះហស្តដាក់ចេញ ពីបាត្រហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនន្ទមាតាឧបាសិកា អង្គុយក្នុងទីដ៏សមគួរហើយព្រះសារីបុត្រដ៏មានអាយុក៏សួរដូច្នេះ ថា ម្នាលនន្ទមាតា ចុះអ្នកណាប្រាប់ដំណើរមកនៃភិក្ខុសង្ឃដល់ នាង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ក្រោកឡើងក្នុងបច្ចូស- សម័យនៃរាត្រីឯណោះ សូត្របារាយនធម៌ដោយសំឡេង (ដ៏ ពីរោះ) ហើយនៅស្ងៀម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ស្រាប់តែ

មហារាជឈ្មោះវេស្សវ័ណ ដឹងច្បាស់នូវទីបំផុតនៃធម្មកថារបស់ខ្ញុំក៏អនុមោទនាថា ម្នាលនាង ពីរោះណាស់ ម្នាលនាង ពីរោះណាស់ ។ ខ្ញុំជាមហារាជឈ្មោះវេស្សវណ ជាប្អូននៃនាង។ បពិត្រព្រះអង្គមានព្រះភ័ក្ត្រដ៏ចម្រើន ការមករបស់ព្រះអង្គប្រពៃណាស់ បើដូច្នោះ ធម្មបរិយាយដែលខ្ញុំបានពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។ ម្នាលនាង ប្រពៃហើយពាក្យនុ៎ះឯង សូមជាបណ្ណាការយ៉ាងវិសេសដល់ខ្ញុំ ភិក្ខុសង្ឃមានព្រះសារីបុត្រនិងព្រះមោគ្គល្លានជាប្រធានមិនទាន់ធ្វើភត្តកិច្ចក្នុងវេលាព្រឹកនៅឡើយ និមន្តមកកាន់វេឡុកណ្ដកនគរក្នុងថ្ងៃស្អែក ចូរនាងអង្គាសភិក្ខុសង្ឃហើយ ឧទ្ទិសជូនចំណែកបុណ្យដល់ខ្ញុំផង។ បណ្ណាការយ៉ាងវិសេសនឹងមានដល់ខ្ញុំយ៉ាងនេះឯង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បុណ្យក្នុងទាននេះ សូមឱ្យជាបុណ្យដែលខ្ញុំបូជាហើយ ដើម្បីសេចក្ដីសុខដល់មហារាជឈ្មោះវេស្សវ័ណចុះ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ម្នាលនន្ទមាតាចំឡែកណាស់ព្រោះនាងបានចរចាក្នុងទីចំពោះមុខជាមួយនឹងមហារាជឈ្មោះវេស្សវ័ណ ជាទេវបុត្ត មានរិទ្ធិធំយ៉ាងនេះ មានស័ក្តធំយ៉ាងនេះ ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចំឡែករបស់ខ្ញុំទេ នៅមានធម៌ ឯទៀតដែលអស្ចារ្យ ចំឡែករបស់

ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងគ្រានេះខ្ញុំមានកូនប្រុសម្នាក់ ឈ្មោះនន្ទៈ ជាទីស្រឡាញ់ ជាទីពេញចិត្ត ព្រះរាជាទាំងឡាយ ចាប់ទាញកំហែងកូននោះ ព្រោះហេតុនីមួយ មកផ្តាច់ជីវិត បពិត្រ លោកម្ចាស់ដ៏ចម្រើន កាលទារកនោះ គេចាប់យកទៅហើយក្តី កំពុងចាប់ក្តី សម្លាប់ហើយក្តី កំពុងសម្លាប់ក្តី បៀតបៀនហើយក្តី កំពុងបៀតបៀនក្តីខ្ញុំម្ចាស់មិនដឹងនូវសេចក្តីប្រែប្រួលនៃចិត្តឡើយ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ម្នាលនន្ទមាតា ចំឡែក ណាស់ កោតតែនាងជំរះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែន អស្ចារ្យ ចំឡែករបស់ខ្ញុំទេ នៅមានធម៌ឯទៀតដែលអស្ចារ្យ ចំឡែក របស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងគ្រានេះ ស្វាមីរបស់ខ្ញុំធ្វើ មរណកាលទៅ ក៏ទៅកើតក្នុងកំណើតនៃយក្សមួយ ស្វាមីរបស់ ខ្ញុំនោះ សំដែងនូវអត្តភាពដល់ខ្ញុំដូចក្នុងកាលមុន បពិត្រលោក ម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់មិនដឹងនូវសេចក្តីប្រែប្រួលនៃចិត្តដែលជា ហេតុជាងនោះឡើយ ។

សា. ម្នាលនន្ទមាតាអស្ចារ្យណាស់ ម្នាលនន្ទមាតាចំឡែក ណាស់ កោតតែនាងជំរះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យ ចំឡែករបស់ខ្ញុំទេ នៅមានធម៌ឯទៀតដែលអស្ចារ្យ ចំឡែករបស់

ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់នៅក្រមុំ គេនាំមកឱ្យស្វាមីកំឡោះ ខ្ញុំមិនដែលប្រព្រឹត្តកន្លងដោយចិត្តទេ មិនបាច់និយាយដល់ការប្រព្រឹត្តកន្លងដោយកាយឡើយ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចំឡែកណាស់ កោតតែនាងជំរះនូវហេតុត្រឹមតែការកើតឡើងនៃចិត្តបាន ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចំឡែករបស់ខ្ញុំទេ នៅមានធម៌ឯទៀតដែលអស្ចារ្យចំឡែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំសំដែងខ្លួនជាឧបាសិកាឡើង មិនធ្លាប់ក្លែងប្រព្រឹត្តកន្លងសិក្ខាបទណាមួយទេ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចំឡែកណាស់ ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចំឡែករបស់ខ្ញុំទេ នៅមានធម៌ឯទៀតដែលអស្ចារ្យ ចំឡែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ប៉ុនប៉ងដរាបមកក្នុងទីនេះថា ខ្ញុំស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិត្តកៈ និងវិចារៈ មានបីតិនិងសុខ កើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់នូវកាមវិត្តកៈ និងវិចារៈក៏បានដល់ទុតិយជ្ឈាន ជាធម្មជាតិកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធាមានសភាពជាចិត្ត

ខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះវិនាសទៅនៃបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង ខ្ញុំជាអ្នកនឹករលឹកដឹងច្បាស់ ទទួលនូវសុខដោយនាមកាយផង បានដល់នូវតតិយជ្ឈាន ដែលអរិយៈទាំងឡាយតែងសរសើរថា បុគ្គលមានសតិប្រកបដោយឧបេក្ខា នៅជាសុខ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង វិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ខ្ញុំក៏បានដល់នូវចតុត្ថជ្ឈានមានសតិដ៏បរិសុទ្ធដោយឧបេក្ខាមិនជាទុក្ខ មិនជាសុខ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចំឡែកណាស់ ។

ន. បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចំឡែករបស់ខ្ញុំទេនៅមានធម៌ឯទៀតដែលអស្ចារ្យ ចំឡែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន សំយោជនៈខាងក្រោមទាំង ៥ ណាដែលព្រះមានព្រះភាគទ្រង់សំដែងហើយបណ្តាសំយោជនៈទាំងនោះខ្ញុំម្ចាស់ពិចារណាមិនឃើញនូវសំយោជនៈណាមួយក្នុងខ្លួនដែលមិនទាន់លះបង់សោះឡើយ ។

សា. ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចំឡែកណាស់ ។

លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ញុំាងនន្ទមាតា

ឧបាសិកាឱ្យឃើញច្បាស់ ឱ្យប្រតិបត្តិតាម ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថា ហើយក្រោកចាកអាសនៈចេញទៅ ។

**ការចែកចំណែកផលបុណ្យនេះមាន ២ ប្រភេទគឺ**

បើយើងចែកចំណែកផលបុណ្យនេះ ដល់អ្នកដែលកំពុងរស់នៅ ដូចគ្នា ហៅថា ប្រគេន ថ្វាយ ឬជូន ។

នេះជាពាក្យសម្រាប់ជូនបុណ្យដល់គ្នានិងគ្នា ។

**អ្នកជូនត្រូវលើកដៃសំពះរួចពោលថា៖**

បុណ្យកុសលឯណាដែលខ្ញុំបានធ្វើហើយ (អាចរៀបរាប់ឈ្មោះបុណ្យនោះ ផងក៏បាន) ខ្ញុំសូម(ប្រគេន ថ្វាយ ឬជូន)នូវចំណែកផលបុណ្យនោះដល់(អ្នកណាមួយ ដែលយើងចង់ជូន) សូម(....) បានអនុមោទនា ត្រេកអរទទួលយកនូវចំណែកផលបុណ្យរបស់ខ្ញុំនេះផងចុះ !

ចំណែកអ្នកទទួល ត្រូវទទួលយកដោយចិត្តជ្រះថ្លា រីករាយថា សាធុ ! សាធុ ! សាធុ ! បីដងយ៉ាងនេះ ។

ឧទាហរណ៍ថា កូនប្រុសស្រីជូនបុណ្យដល់ឪពុកម្តាយ គឺត្រូវក្រាបសំពះពួកគាត់បីដង លើកដៃប្រណម រួចពោលជូនបុណ្យទៅគាត់យ៉ាងនេះថា៖

បុណ្យកុសលឯណាដែលកូនបានធ្វើហើយ (មានការឱ្យទានជាដើម) កូនសូមជូននូវចំណែកផលបុណ្យនោះ ដល់លោក

ឪពុកអ្នកម្តាយ សូមលោកឪពុកអ្នកម្តាយ អនុមោទនា ត្រេកអរនូវចំណែកផលបុណ្យនេះរបស់កូនផងចុះ !

បើចែកចំណែកផលបុណ្យដល់អ្នកដទៃដែលស្លាប់ ចែកបានទៅហើយ ហៅថា ឧទ្ទិស ។

នេះជាពាក្យសម្រាប់ឧទ្ទិសផលបុណ្យដល់អ្នកស្លាប់ ត្រូវតាំងចិត្តឧទ្ទិសចេញពីក្នុងចិត្តពិតៗ ដោយពោលវាចាថា៖

បុណ្យកុសលឯណាដែលខ្ញុំបានធ្វើហើយ(រៀបរាប់ឈ្មោះបុណ្យនោះផងក៏បាន) ខ្ញុំសូមឧទ្ទិសនូវចំណែកផលបុណ្យនោះជូនដល់ញាតិកា បុព្វការីជនរបស់ខ្ញុំនោះ បានអនុមោទនាត្រេកអរនូវចំណែកផលបុណ្យនេះ ហើយសូមឱ្យបានដល់នូវសេចក្តីសុខចុះ !

**ឬពោលឧទ្ទិសខ្លី ដូចពាក្យបាលីនេះថា៖**

***ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ*** ផលបុណ្យនេះ ចូរមានដល់ញាតិទាំងឡាយរបស់ខ្ញុំ សូមឱ្យញាតិទាំងឡាយរបស់ខ្ញុំ បានដល់នូវសេចក្តីសុខចុះ !

ពេលធ្វើបុណ្យរួចហើយ កុំភ្លេចជូនផលបុណ្យនោះដល់សព្វសត្វទូទៅទាំងអស់ផង ជាពិសេសកុំភ្លេចជូនដល់ព្រះឥន្ទ្រាធិរាជ ស្តេចទេវតា ស្តេចចតុលោកបាលទាំងបួន និងស្តេចយមរាជផងណា...!ពីព្រោះទេវតាត្រូវការបុណ្យណាស់ពេញចិត្ត

នឹងបុណ្យណាស់ អំពីមនុស្សដែលបានធ្វើបុណ្យ ។ ឯចំណែកស្តេចយមរាជវិញ រឹតតែសំខាន់ទៅទៀត ព្រោះក្រែងលោគ្នាត់គតិណាមួយបានទៅជួបជាមួយស្តេចមយរាជ, គ្រានោះស្តេចយមរាជនឹងសួរថា អ្នកធ្លាប់បានធ្វើបុណ្យអ្វីខ្លះ ខណៈនោះបើយើងនឹកឃើញដល់បុណ្យ យើងនឹងរួចផុតអំពីនរកភ្លាម តែបើយើងនឹកមិនឃើញទេ ស្តេចយមរាជនឹងរំពឹងគិតថា តើអ្នកនេះធ្វើបុណ្យហើយ ធ្លាប់ផ្សាយចំណែកផលបុណ្យដល់អាត្មាអញទេ បើយើងធ្លាប់ផ្សាយផលបុណ្យដល់ស្តេចយមរាជ, ស្តេចយមរាជនឹងប្រាប់ដល់យើងភ្លាមហើយយើងនឹងរួចផុតអំពីសេចក្តីទុក្ខភ្លាម។

## បត្តិទានមយៈ ចប់

## គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៥៥៧

អដ្ឋកថាពន្យល់សេចក្ដីនៃគម្ពីរព្រះត្រៃបិដក ព.ស. ២៥២២

គម្ពីរឃ្លាំងបរិយត្តិភាគ ១២ ព.ស. ២៥៤៧

គម្ពីរធម្មាវលី របស់ភិក្ខុ ធម្មវរាចារ្យ

គម្ពីរបរមត្ថជោតិកា បរិច្ឆេទទី ៥ ក្បាលទី ១ ព.ស. ២៥៤០

បុញ្ញកិរិយាវត្ថុ លោកគ្រូ ភួង សុវណ្ណ ព.ស. ២៥៥៥

វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១

ព្រមទាំងឯកសាមួយចំនួន

# ព្រះពុទ្ធដីកា

***មនុស្សជាបណ្ឌិតជាតិ*** *រមែងសម្រេចនូវការនៅក្នុងប្រទេសណាហើយ ក៏តែងឲ្យពួកបុគ្គលមានសីល ដែលសង្រួមល្អ ប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគក្នុងលំនៅរបស់ខ្លួន ហើយបានទាំងឧទ្ទិសផលទក្ខិណាទាន (ឲ្យចំណែកបុណ្យ)ដល់ពួកទេវតាដែលនៅក្នុងប្រទេសនោះ (ថែមទៀត)។*

***ទេវតាទាំងនោះ*** *តែងបូជាចំពោះមនុស្សដែលបានបូជាដល់ខ្លួន តែងរាប់អានចំពោះមនុស្សដែលរាប់អានដល់ខ្លួន តែងអនុគ្រោះមនុស្សនោះ ដូចជាមាតាអនុគ្រោះបុត្រដែលខ្លួនបីថ្នម ផ្ចាប់នឹងទ្រូងឲ្យចម្រើនឡើង ។ មនុស្សដែលទេវតាបានអនុគ្រោះហើយ ក៏តែងឃើញនូវសេចក្តីចម្រើនសព្វៗកាល ។*